**វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា**
**International Relations Institute of Cambodia**

# ការបោះឆ្នោតឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅព្រះរាជាណាចក្រកម្ពុជា


**លោក អ៊ុច លាង**
**នាយកដ្ឋាន សិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា**



**ភ្នំពេញ ខែមិថុនា ឆ្នាំ២០២២**

# ការបោះឆ្នោតឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
# នៅព្រះរាជាណាចក្រកម្ពុជា

សេចក្ដីផ្ដើម ........ ៣
១. យុទ្ធនាការឃោសនារកសម្លេងឆ្នោត ........ ៥
២. អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ........ ៦
៣. ពាក្យបណ្ដឹង ........ ៨
៣.១. ពាក្យបណ្ដឹងអំឡុងពេលឃោសនា ........ ៨
៣.២. ពាក្យបណ្ដឹងអំឡុងពេលបោះឆ្នោត ........ ៨
៤. ប្រតិកម្មនានាពីសំណាក់ គណបក្សនយោបាយ អង្គការជាតិ អន្តរជាតិ និងសង្គមស៊ីវិល ........ ៩
៤.១. គណបក្សនយោបាយ ........ 10
៤. ២. អង្គការជាតិ អន្តរជាតិ និងសង្គមស៊ីវិល ........ ១៦
៥. គោលនយោបាយរបស់បក្សធំៗ២ ........ ២៧
៥.១. គោលនយោបាយគណបក្សប្រជាជន ........ ២៧
៥.២. គោលនយោបាយគណបក្សភ្លើងទៀន ........ ២៨
៦. លទ្ធផលនៃការបោះឆ្នោត និងបញ្ហាពាក់ព័ន្ធ ........ ៣០
៦.១. លទ្ធផលបោះឆ្នោតផ្លូវការ ........ ៣០
៦.២. ស្ថានភាពក្រោយប្រកាសលទ្ធផលផ្លូវការ ........ ៣១
៦.៣. ស្ថានភាពគណបក្សប្រឆាំង ក្រោយការរំលាយ គណបក្ស សង្គ្រោះជាតិ ដោយអំណាចតុលាការកំពូល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ........ ៣៩
សេចក្ដីសន្និដ្ឋាន ........ ៤២

## សេចក្ដីផ្ដើម

ក្រុមប្រឹក្សាឃុំសង្កាត់គឺជាអង្គការតំណាងប្រជាពលរដ្ឋ ដែលត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតរបស់ប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន ហើយមានបេសកកម្មបម្រើ ផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ចាប់ផ្ដើមដំណើរការជាលើកដំបូងនៅ ឆ្នាំ២០០២ និងត្រូវបានអនុវត្តជាបន្តបន្ទាប់រៀងរាល់៥ឆ្នាំម្ដង ហើយបើគិតមកទល់ឆ្នាំ២០២២នេះ គឺសម្រេចបានចំនួន៥អាណត្តិ។

ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥នេះ ត្រូវបានប្រមុខរាជរដ្ឋាភិបាលកំណត់ ជ្រើសយក ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ជាកាលបរិច្ឆេទនៃការបោះឆ្នោត។ នេះបើយោងតាមសេចក្ដី សម្រេច របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១កន្លងទៅ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានបិទបញ្ចប់ជាផ្លូវការ នៅម៉ោង៣រសៀល ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ដែលមានពលរដ្ឋទៅចូលរួមបោះឆ្នោតចំនួន ៧,៣៩៤,៤២៧នាក់ ស្មើប្រមាណ ៨០.៣២% នៃពលរដ្ឋដែល មានឈ្មោះក្នុងបញ្ជីបោះឆ្នោត នាឆ្នាំ២០២១ ដែលមានចំនួនសរុប ៩.២០៥.៦៨១នាក់ ដែលជា អត្រាមួយ ដែលមានអ្នកទៅចូលរួល បោះឆ្នោតច្រើនគួរសម បើធៀបនឹង បណ្ដាប្រទេសផ្សេង ប៉ុន្តែមានអត្រាទាបជាង កាលណីអាណត្តិទី៤ ដែលមានអ្នកទៅចូលរួមបោះឆ្នោតរហូតប្រមាន ៩០.៣៧%។[១] ចំណែកពលរដ្ឋ ចំនួនប្រមាណ២លាននាក់ ដែលមិនបានចូលរួមបោះឆ្នោតគឺ អាចដោយសារបញ្ហាធាតុអាកាស និងពលរដ្ឋមួយចំនួនទៀតឯក្រៅ ប្រទេស។[២]

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ មានគណបក្សនយោបាយចូលរួម ចូលរួមសរុបចំនួន១៧ (១. គណបក្សប្រជាជនកម្ពុជា, ២. គណបក្សភ្លើងទៀន, ៣. គណបក្សហ៊្វុនស៊ិនប៉ិច, ៤. គណបក្សខ្មែររួបរួមជាតិ, ៥. គណបក្សខ្មែរស្រឡាញ់ជាតិ, ៦. គណបក្សសញ្ជាតិកម្ពុជា, ៧. គណបក្សយុវជនកម្ពុជា, ៨. គណបក្សកែទម្រង់កម្ពុជា, ៩. គណបក្សឆន្ទៈខ្មែរ, ១០. គណបក្សកម្ពុជានិយម, ១១. គណបក្សប្រជាធិបតេយ្យមូលដ្ឋាន, ១២. គណបក្សខ្មែរតែមួយ, ១៣. គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, ១៤. គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា, ១៥. គណបក្សឯកភាពជាតិខ្មែរ, ១៦. គណបក្សរស្មីខេមរា, ១៧. គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច)។ ការបោះឆ្នោតឃុំសង្កាត់អាណត្តិទី៥ មានបេក្ខជនឈរឈ្មោះសរុបចំនួន ប្រមាណ ៨២,៧០០នាក់ សម្រាប់ឃុំសង្កាត់សរុបចំនួន ១,៦៥២ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សរុបចំនួន ១១,៦២២

---

[១] RFI, "បោះឆ្នោតឃុំសង្កាត់៖ គ.ជ.ប វាយតម្លៃថាប្រក្រតី ដោយពលរដ្ឋជិត៧៨%ទៅបោះឆ្នោត", 05/06/2022, https://rfi.my/8TaP, ( accessed date 28-June-2022 at 10 AM)

[២] Fresh News, "គ.ជ.ប ប្រកាសលទ្ធផលបណ្ដោះអាសន្ន ប្រជាពលរដ្ឋ ៨០.១៩ភាគរយ បានចេញទៅបោះឆ្នោត", "2022-06-06", http://freshnewsasia.com/index.php/en/localnews/245082-2022-06-06-10-44-36.html ( accessed date 28-June-2022 at 10 AM)

អាសនៈ។[៣] គណបក្សប្រជាជនកម្ពុជាតែមួយគត់ ដែលមានបេក្ខជនឈរ ឈ្មោះគ្រប់ខេត្តក្រុង បន្ទាប់គឺគណបក្សភ្លើងទៀន។

សូមរំលឹកថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ចាប់ផ្តើមដំណើរការជាលើកដំបូងនៅឆ្នាំ២០០២ ដែលជាអាណត្តិទី១ ត្រូវបានធ្វើឡើងជាសកល និងដោយផ្ទាល់ សម្រាប់ឃុំនិងសង្កាត់ បន្ទាប់មកអនុវត្តជាបន្តបន្ទាប់រៀងរាល់៥ឆ្នាំម្តង គឺ អាណត្តិទី២(២០០៧) អាណត្តិទី៣(២០១២) អាណត្តិទី៤(២០១៧) និងអាណត្តិទី៥(២០២២)នេះ ដែលបានជ្រើសយកថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២២ ជាថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាស លទ្ធផល បណ្តោះអាសន្ន។[៤]

កាលពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ កន្លងទៅ គណបក្សនយោបាយដែលចូលរួម ការបោះឆ្នោតនៅទូទាំងប្រទេសដែលមាន២៥ខេត្តក្រុង មានគណបក្សចូលរួមសរុបចំនួន១២ (១-គណបក្សប្រជាជនកម្ពុជា, ២-គណបក្សសង្គ្រោះជាតិ, ៣-គណបក្សហ្វ៊ុន ស៊ិន ប៉ិក, ៤-គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ, ៥-គណបក្ស ខ្មែររួបរួមជាតិ, ៦-គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, ៧-គណបក្សសញ្ជាតិកម្ពុជា, ៨-គណបក្សប្រជាធិបតេយ្យ មូលដ្ឋាន, ៩-គណបក្ស សាធារណរដ្ឋ ប្រជាធិបតេយ្យ, ១០-គណបក្សយុវជនកម្ពុជា, ១១-គណបក្ស អំណាចខ្មែរ, និង ១២-គណបក្ស ជនជាតិ ដើមប្រជាធិបតេយ្យកម្ពុជា)។ នៅក្នុងការបោះឆ្នោតកន្លងទៅនោះ មានតែគណបក្សចំនួន២ ប៉ុណ្ណោះដែល មានឥទ្ធពលក្នុងការបោះឆ្នោត គឺគណបក្ស ប្រជាជនកម្ពុជា ទទួលបានចំនួន ៣.៥៤ លានសម្លេង និងទទួល បានតំណែងមេឃុំ ចំនួន១១៥៦ និងអាសនៈក្រុមប្រឹក្សា ៦៥០៣ ខណៈដែល គណបក្សសង្គ្រោះជាតិ ទទួលបាន ៣.០៦ លានសម្លេង និងទទួលបានតំណែង មេឃុំចំនួន ៤៨៩ និងអាសនៈក្រុមប្រឹក្សាចំនួន ៥០០៧។[៥]

សម្រាប់ការបោះឆ្នោត ជ្រើសតាំងសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៤ នាឆ្នាំ២០១៧ កន្លងទៅ យើងសង្កេតឃើញថា ប្រព្រឹត្តទៅដោយរលូន ប្រកបដោយសុខសន្តិភាព និងមានភាពល្អប្រសើជាងពេលបោះឆ្នោតមុនៗ និងមានអ្នកទៅបោះឆ្នោតប្រមាណ ៩០.៣៧% បានចេញទៅបោះឆ្នោត

---

[៣] The National Election Committee (NEC), "សេចក្តីប្រកាស លេខ ០០២ គ.ជ.ប.ប្រ.ក ស្តីពី ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២", https://www.nec.gov.kh/khmer/content/4940, (accessed date 20-June-2022 at 10 AM)

[៤] The Natioanl Election Committee(NEC), "ប្រតិទិនបោះឆ្នោត",
https://www.nec.gov.kh/khmer/taxonomy/term/253 (accessed date 20-June-2022 at 10 AM)

[៥] The Natioanl Election Committee(NEC), "តារាងគណបក្សនយោបាយទទួលបានអាសនៈ នៃ លទ្ធផលផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧", https://www.nec.gov.kh/khmer/content/4457, (accessed date 21-June-2022 at 10 AM)

បើធៀប នឹងចំនួនអ្នកដែលបានចុះឈ្មោះបោះឆ្នោត និងប្រកបដោយទឹកមុខរីករាយ គ្មានការភិតភ័យ និងភ័យខ្លាច។ នេះបើយោងតាមសេចក្តីថ្លែងការណ៍ របស់ គ.ជ.ប អាណត្តិទី៤ ឆ្នាំ២០១៧។[៦]

## ១. យុទ្ធនាការឃោសនារកសម្លេងឆ្នោត

ការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ មានរយៈពេល១៤ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២។

យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ មានបញ្ហាមិនប្រក្រតីកើតឡើងតិចតួច។ តែទោះជាយ៉ាងនេះក្តី គ.ជ.ប បានបញ្ជាក់ថា មានបញ្ហាមិនប្រក្រតីមួយចំនួន បានកើតមាន តែក៏មិនឈានដល់កើតមានអំពើហិង្សាឡើយ។ គ.ជ.ប បានវាយតម្លៃពីសភាពការណ៍ ទូទៅនៃ យុទ្ធនាការ ឃោសនារកសម្លេងឆ្នោតរបស់គណបក្សនយោបាយទាំង១៧ ថាមានភាពល្អប្រសើរ មិនធ្វើឱ្យប៉ះពាល់ ដល់ដំណើរការឃោសនានោះទេ។

បញ្ហាមិនប្រក្រតីមួយចំនួន ដែលកើតមាននៅអំឡុងពេលយុទ្ធនាការឃោសនារកសម្លេង គាំទ្ររបស់គណបក្សនយោបាយ មានជាអាទិ៍ ការប្រើប្រាស់ពាក្យពេចន៍ជៀមដាម ចោទប្រកាន់ និងរើសអើង ការចាក់មេក្រូឃោសនានៅម៉ោងហាមឃាត់ ការហែកស្លាកគណបក្ស និងបញ្ហាសមាជិក ក្រុមប្រឹក្សាយកម៉ោងប្រចាំការទៅហែក្បួនឃោសនា ឱ្យគណបក្សផ្សេង។ នេះបើតាមការបញ្ជាក់របស់លោក ឌឹម សុវណ្ណារុំ សមាជិក គ.ជ.ប និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប ថ្លែងនៅក្នុងពិធីប្រកាសបិទដំណើរការឃោសនាបោះឆ្នោត នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២។[៧]

រយៈពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនារកសម្លេងឆ្នោត គ.ជ.ប សង្កេតឃើញថា គណបក្សនយោបាយទាំង១៧ បានធ្វើសកម្មភាពយ៉ាងគគ្រឹកគគ្រេងនៅតាមឃុំ-សង្កាត់ ដែលគណបក្សនីមួយៗ បានដាក់បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ គ.ជ.ប កត់សម្គាល់ថា ការហែក្បួន ឃោសនាធំៗរបស់គណបក្សនយោបាយ បានធ្វើឡើងនៅថ្ងៃទី១ នៃការឃោសនា កាលពីថ្ងៃទី២១ ខែឧសភា និងនៅថ្ងៃចុងក្រោយនៃការឃោសនា នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២។

ជាមួយគ្នានេះ គិតត្រឹមថ្ងៃ០២មិថុនា បញ្ហាប្តឹងប្តល់ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត បានកើតមានរហូតដល់៥២ករណី។ ទាំង៥២ករណី ដែលគណៈកម្មការឃុំ-សង្កាត់ រៀបចំការបោះឆ្នោត ទទួល

---

[៦] Fresh News Asia, "គ.ជ.ប ចេញសេចក្តីថ្លែងការណ៍សោកស្តាយយ៉ាងខ្លាំង ចំពោះការវាយតម្លៃខុស ធ្វើឲ្យសាធារណជនយល់ច្រឡំលើដំណើរការនិងលទ្ធផលបោះឆ្នោត, អ្នកបោះឆ្នោត៩០.៣៧% បានទៅបោះឆ្នោតជាមួយទឹកមុខរីករាយ គ្មានការបំផិតបំភ័យ និងគ្មានការភ័យខ្លាច", "June 27, 2017", http://m.freshnewsasia.com/index.php/en/localnews/58353-2017-06-27-11-45-27.html, ( accessed date 28-June-2022 at 10 PM)

[៧] RFI, "គ.ជ.ប ៖ យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ មានបញ្ហាមិនប្រក្រតីកើតឡើងតិចតួច តែមិនធ្ងន់ធ្ងរ", "03/06/2022", "https://rfi.my/8TGQ" ( accessed date 21-June-2022 at 10 AM)

បន្ទុកដោះស្រាយនោះ មាន២១បណ្តឹងដាក់បន្តចូលមកគណៈកម្មាការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងមាន៤បណ្តឹងដាក់មកជំនុំជម្រះសម្រេចនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ភាគច្រើននៃបណ្តឹងទាំងនោះ គឺជាបណ្តឹងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សភ្លើងទៀន។

ទោះយ៉ាងណា គ.ជ.ប បានវាយតម្លៃថា បរិយាកាសឃោសនាស្វែងរកសម្លេងរបស់គណបក្សក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ បានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា ដែលធានានុវសុវត្ថិភាពដល់ បេក្ខជនឈរឈ្មោះ អ្នកចូលរួម និងប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។

គួរជម្រាបថា យុទ្ធនាការឃោសនា បានចាប់ផ្តើមពីថ្ងៃទី២១ឧសភា រហូតដល់ថ្ងៃទី០៣មិថុនា ដែលមានរយៈពេល១៤ថ្ងៃ សម្រាប់ឱ្យគណបក្សនយោបាយ ចេញអួតសាច់ដុំពីគោលនយោបាយ ដើម្បីរកសម្លេងគាំទ្រពីមហាជន។

ដោយឡែកនៅថ្ងៃទី០៤មិថុនា គឺជាថ្ងៃស ដែលគណបក្សនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ត្រូវបញ្ឈប់សកម្មភាពផ្សព្វផ្សាយអំពីគណបក្សរបស់ខ្លួន ដើម្បីកុំឱ្យរំខានដល់ទំនុកចិត្តពលរដ្ឋដែលត្រៀម សម្រាប់ការចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃអាទិត្យទី០៥ ខែមិថុនា ឆ្នាំ២០២២។[៨]

## ២. អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ បានបិទបញ្ចប់ កាលពីល្ងាចថ្ងៃទី០៥ ខែមិថុនា ជាមួយនឹងតម្លាភាព ត្រឹមត្រូវនិងយុត្តិធម៌ និងទទួលបានពីគ្រប់ភាគី ពិសេសបណ្តា គណបក្សនយោបាយដែលបានចូលរួមបោះឆ្នោត។ ការបោះឆ្នោតនេះ មានការចូលរួមសង្កេតការណ៍ ពីសំណាក់បណ្តាស្ថាប័ន អង្គការ សហគមន៍ចំនួន៧២ និងសហគមន៍អន្តរជាតិចំនួន១៩។ ដែលក្នុងនោះមានអ្នកសង្កេតការណ៍ជាតិ សរុបចំនួន ៧៤,៨៨៥រូប មកពី៧២ស្ថាប័ន្ត មកពីសហគមនិងអង្គការអ្នកសង្កេតការណ៍អន្តរជាតិ ចំនួន១១០រូប មកពី១៩ស្ថាប័ន[៩] ព្រមទាំងមានភ្ញៀវពិសេសចំនួន២៣រូប មកពី៥ស្ថាប័នផងដែរ ក្នុងនោះមានស្ថានទូតជប៉ុន អូស្ត្រាលី និងរុស្ស៊ីជាដើម។[១០]

---

[៨] RFI, "គ.ជ.ប ៖ យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ មានបញ្ហាមិនប្រក្រតីកើតឡើងតិចតួច តែមិនធ្ងន់ធ្ងរ", "03/06/2022", "https://rfi.my/8TGQ" (accessed date 21-June-2022 at 10 AM)

[៩] The Natioanl Election Committee(NEC), "លទ្ធផលផ្លូវការនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២", https://www.nec.gov.kh/khmer/content/5826 (accessed date 21-June-2022 at 10 AM)

[១០] Fresh News, "គ.ជ.ប ប្រកាសលទ្ធផលបណ្តោះអាសន្ន ប្រជាពលរដ្ឋ ៨០.១៩ភាគរយ បានចេញទៅបោះឆ្នោត", "2022-06-06", "http://freshnewsasia.com/index.php/en/localnews/245082-2022-06-06-10-44-36.html" (accessed date 21-June-2022 at 10 AM)

សម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥នេះ សហភាពអឺរ៉ុប បានបន្តប្រកាស ថាមិនដាក់អ្នកសង្កេតការណ៍សម្រាប់ការបោះឆ្នោត ដ្បិតមិនមានវត្តមាននៃគណបក្សប្រឆាំង។[១១]

ចំណែក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានវាយតម្លៃពី សភាពការណ៍ទូទៅនៃយុទ្ធនាការឃោសនារកសម្លេងឆ្នោតរបស់គណបក្សនយោបាយទាំង១៧ ថាមានភាពល្អប្រសើរ មិនធ្វើឱ្យប៉ះពាល់ដល់ដំណើរការឃោសនានោះទេ។ តែទោះជាយ៉ាងនេះ គ.ជ.ប បញ្ជាក់ថា មានបញ្ហាមិន ប្រក្រតីមួយចំនួនបានកើតមាន តែក៏មិនឈានដល់កើតមានអំពើហិង្សា។[១២]

សូមជម្រាបថា អ្នកសង្កេតការណ៍អន្តរជាតិ ដែលចូលរួមសង្កេតការណ៍ក្នុងការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ រួមមាន៖ ទី១៖ តំណាងអង្គការអ្នក ប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ (Centralist Democrat International CDI-IDC)។ ទី២៖ តំណាងអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិប្រចាំអាស៊ីប៉ាស៊ីហ្វិក (Centralist Asia-Pacific Democrat International - CAPDI)។ ទី៣៖ តំណាងអង្គការសន្និសិទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី (International Conference of the Asian Political Parties - ICAPP)។ ទី៤៖ តំណាងវេទិកាស្ថាប័នស្រាវជ្រាវសកល 2022 (Think Tank 2022 Global Forum)។ ទី៥៖ តំណាងសហគមន៍អន្តរសភាអាស៊ាន (ASEAN Inter-Parliament Association - AIPA)។ ទី៦៖ តំណាងសភាអន្តរជាតិដើម្បីសន្តិភាព និងភាពអត់ឱន (International Parliament for Tolerance and Peace - IPTP)។ ទី៧៖ តំណាងក្រុមអ្នកសង្កេតការណ៍ឯករាជ្យ (Independence Observer)។ ទី៨៖ តំណាងសហគមន៍ខ្មែរនៅក្រៅប្រទេស រួមមាន សហគមន៍ខ្មែរវេលីងតុន (Khmer Culture Association of Wellington Inc. New Zealand) និងសហគមន៍ខ្មែរនៅកូរ៉េ ជាដើម។[១៣]

---

[១១] RFI, "បោះឆ្នោតឃុំ-សង្កាត់៖ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ថា សេរី យុត្តិធម៌ តែអង្គការអន្តរជាតិខ្លះ ថា មិនមានប្រជាធិបតេយ្យ", "06/06/2022", https://rfi.my/8TgO (accessed date 21-June-2022 at 10 AM)

[១២] RFI, "គ.ជ.ប ៖ យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ មានបញ្ហាមិនប្រក្រតីកើតឡើងតិចតួច តែមិនធ្ងន់ធ្ងរ", "03/06/2022", "https://rfi.my/8TGQ" (accessed date 21-June-2022 at 10 AM)

[១៣] Fresh News, "លោក ឌឹម សុវណ្ណារុំ បង្ហាញលទ្ធផលនៃបទបង្ហាញស្តីពី «ស្ថានការណ៍នយោបាយ និងដំណើរការបោះឆ្នោតនៅកម្ពុជា ជូនដល់អ្នកសង្កេតការណ៍អន្តរជាតិ»", "2022-06-04", "http://freshnewsasia.com/index.php/en/localnews/244864-2022-06-04-10-50-01.html" (accessed date 21-June-2022 at 10 AM)

## ៣. ពាក្យបណ្តឹង

### ៣.១. ពាក្យបណ្តឹងអំឡុងពេលឃោសនា

ក្នុងអំឡុងពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនារកសម្លេងឆ្នោត ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ មានគណបក្សនយោបាយទាំង១៧ បានធ្វើសកម្មភាពយ៉ាង គគ្រឹកគគ្រេង នៅតាមឃុំ-សង្កាត់ ដែលគណបក្សនីមួយៗ បានដាក់បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ នេះបើ យោងតាមការវាយតម្លៃរបស់ គ.ជ.ប។

នៅក្នុងខ្លឹមសារផ្សព្វផ្សាយរបស់ ឯកឧត្តម ឌឹម សុវណ្ណារុំ សមាជិក គ.ជ.ប ក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ បានឱ្យដឹងថា គិតត្រឹមថ្ងៃ០៣ ខែមិថុនា មានបញ្ហាប្តឹងប្តល់ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត បានកើតមានរហូតដល់៥២ករណី។ ទាំង៥២ករណី[១៤] ដែលគណៈកម្មការឃុំ-សង្កាត់ រៀបចំការបោះឆ្នោត ទទួលបន្ទុកដោះស្រាយនោះ មាន២១បណ្តឹង បានដាក់បន្តចូលមកគណៈកម្មការរាជធានី/ខេត្ត រៀបចំការបោះឆ្នោត និងមាន៤បណ្តឹង បានដាក់មកជំនុំជម្រះសម្រេចនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ភាគច្រើននៃ បណ្តឹងទាំង នោះ គឺជាបណ្តឹងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សភ្លើងទៀន។ ទោះជាយ៉ាងណា គ.ជ.ប បានធ្វើការវាយតម្លៃថា បរិយាកាសឃោសនាស្វែងរកសម្លេងឆ្នោតរបស់គណបក្សទាំងអស់ ក្នុងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ បានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា ដែលធានាបាននូវសុវត្ថិភាពដល់ បេក្ខជនឈរឈ្មោះ អ្នកចូលរួម និងប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោត។ [១៥]

### ៣.២. ពាក្យបណ្តឹងអំឡុងពេលបោះឆ្នោត

ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ កន្លងទៅនេះ គ.ជ.ប ទទួលបានបណ្តឹង សរុបចំនួន ១៤២ បណ្តឹង ដែលជាបណ្តឹងទាក់ទងនឹង ថ្ងៃសៅរ៍ (មួយថ្ងៃមុនថ្ងៃបោះឆ្នោតឬថ្ងៃស) និងនៅថ្ងៃបោះឆ្នោត គឺថ្ងៃអាទិត្យទី៥ ខែមិថុនា ឆ្នាំ២០២២។ នៅក្នុងចំណោមបណ្តឹងទាំងនោះមាន នៅថ្នាក់ឃុំ-សង្កាត់រៀបចំការបោះឆ្នោតចំនួន៨០បណ្តឹង ប្តឹងផ្ទាល់ទៅគណៈកម្មការរាជធានី-ខេត្តចំនួន ៥៦បណ្តឹង និងប្តឹងផ្ទាល់មក គ.ជ.ប. ចំនួន១បណ្តឹង។ ក្នុងចំណោមបណ្តឹងទាំង ១៤២ នេះ មាន៨៥បណ្តឹង ជាករណីប្តឹងសុំផ្តន្ទាទោស ៥៣បណ្តឹង ជាករណីប្តឹងភាពមិនប្រក្រតី នៅមុនមួយថ្ងៃ( ថ្ងៃស ) និងនៅថ្ងៃបោះឆ្នោតចំនួន ៣២បណ្តឹង។

---

[១៤] RFI, "គ.ជ.ប ៖ យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ មានបញ្ហាមិនប្រក្រតីកើតឡើងតិចតួច តែមិនធ្ងន់ធ្ងរ", "03/06/2022", "https://rfi.my/8TGQ" ( accessed date 21-June-2022 at 10 AM)

[១៥] The Natioanl Election Committee( NEC ), "ខ្លឹមសារផ្សព្វផ្សាយរបស់ ឯកឧត្តម ឌឹម សុវណ្ណារុំ សមាជិក គ.ជ.ប ក្នុនកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ", https://www.nec.gov.kh/khmer/sites/default/files/speech-03-06-2022.pdf ( accessed date 21-June-2022 at 10 AM)

សូមបញ្ជាក់ថា គ.ជ.ប ឈប់ទទួលពាក្យបណ្ដឹងនៅត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៥និង៣០នាទីរសៀល។ ដូច្នេះប្រសិនបើ មកដល់ម៉ោងកំណត់នៅមានបណ្ដឹង គ.ជ.ប នឹងពន្យាពេលវេលា ៤ថ្ងៃយ៉ាងយូរបំផុត ដើម្បីដោះស្រាយទៅលើបណ្ដឹង ថាតើបណ្ដឹងនោះ ត្រូវដោះ ស្រាយតាមរបៀបសវនាការសង្ខេប ឬ សវនាការសាធារណៈ ឬ ធ្វើលិខិតជូនដំណឹងយ៉ាងណានោះ អាស្រ័យទៅលើអង្គហេតុ និងអង្គច្បាប់ ដែលក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ត្រូវធ្វើការពិចារណា។[១៦]

យោងតាមអ្នកនាំពាក្យ គ.ជ.ប. លោក សោម សូរីដា បញ្ជាក់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ថា បណ្ដឹងដែលដាក់នៅគណៈកម្មការរាជធានី-ខេត្ត រៀបចំការបោះឆ្នោតត្រូវបានដោះស្រាយបញ្ចប់សព្វគ្រប់ហើយ។ ដោយឡែក គ.ជ.ប. ដែលទទួលបានបណ្ដឹងចំនួន១៨ ប្ដឹងបន្តពីរាជធានី-ខេត្ត និង ១ ទៀត ប្ដឹងផ្ទាល់មក គ.ជ.ប. ក៏ត្រូវបានដោះស្រាយចប់សព្វគ្រប់ផងដែរ។ ដូច្នេះ ក្រោយពី គ.ជ.ប. បានដោះស្រាយបណ្ដឹងរួចរាល់សព្វគ្រប់ហើយ គ.ជ.ប. អាចប្រកាសលទ្ធផលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នេះជាផ្លូវការបានហើយ។[១៧]

ជារួមយើងសង្កេតឃើងថា ចាប់តាំពីដំណាក់កាលឃោសនា រហូតដល់ថ្ងៃបោះឆ្នោត ប្រកាសលទ្ធផលបឋម និងប្រកាសលទ្ធផលផលផ្លូវការ ថ្វីត្បិតតែមានពាក្យបណ្ដឹងសរុបប្រមាណ២០០បណ្ដឹង ដែលភាគច្រើន ជាបណ្ដឹងរវាង គណបក្សប្រជាជនកម្ពុជា និងគណបក្សភ្លើងទៀនក៏ដោយ ប៉ុន្តែសុទ្ធតែបានដោះស្រាយចប់សព្វគ្រប់ និងទាន់ពេលវេលា។ នេះពិតជាបង្ហាញពីភាពចាស់ទុំ ទាំង គ.ជ.ប ទាំងម្ចាស់ឆ្នោត ទាំងគណបក្សដែលចូលរួមប្រកួតប្រជែង ទាំងអ្នកសង្កេតជាតិ និងអន្តរជាតិ និងបានធ្វើឱ្យដំណើរការ បោះឆ្នោតប្រព្រឹត្តទៅបានដោយរលូន និងប្រកបដោយភាពជោគជ័យ។

## ៤. ប្រតិកម្មនានាពីសំណាក់ គណបក្សនយោបាយ អង្គការជាតិ អន្តរជាតិ និងសង្គមស៊ីវិល

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥កន្លងទៅនេះ មានការលើកឡើងខុសៗគ្នាពីសំណាក់គណបក្សនយោបាយ អង្គការ ស្ថាប័ន្តជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងដំណើរប្រព្រឹត្តទៅនៃការរៀបចំ និងការបោះឆ្នោត។

---

[១៦] កម្ពុជាថ្មី, "ពេលវេលាទទួលពាក្យបណ្ដឹងជុំវិញការបោះឆ្នោត នឹងត្រូវបញ្ចប់ត្រឹមល្ងាចថ្ងៃទី ១៧ ខែមិថុនានេះ", "sopheak khoun", "ថ្ងៃសុក្រ ១៧ មិថុនា ២០២២", "https://www.kampucheathmey.com/local-news/329947" ( accessed date 21-June-2022 at 10 AM)

[១៧] ភ្នំពេញប៉ុស្តិ៍, "គ.ជ.ប បញ្ចប់ការដោះស្រាយបណ្ដឹងចំនួន ១៨ ពាក់ព័ន្ធការបោះឆ្នោតឃុំ-សង្កាត់", "នៅ ស៊ីវុត្ថា", "21 June 2022", "https://www.postkhmer.com/national/2022-06-21-1028-237926.html" ( accessed date 21-June-2022 at 10 AM)

## ៤.១. គណបក្សនយោបាយ

គណបក្សនយោបាយ ដែលបានចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា បានចេញមកប្រកាសពីស្ថានភាពនៃដំណើរការនៃការបោះឆ្នោត ទៅតាមការយល់ឃើញរបស់ពួកគេរៀងៗខ្លួន ដោយមួយចំនួន បានលើកឡើងថាការបោះឆ្នោតនេះប្រព្រឹត្ត ទៅយ៉ាងល្អនិងទទួលយកលទ្ធផលនៃការបោះឆ្នោតនេះ ដោយបានបញ្ជាក់ថា ដំណើរការ នៃការបោះឆ្នោតនេះ បានប្រព្រឹត្តទៅប្រកបដោយភាពរលូន គ្មានការរំខាន សេរី ត្រឹមត្រូវ និងយុត្តិធម៌។ គណបក្សមួយចំនួនទៀតចាត់ទុកថា លទ្ធផលនេះ មិនឆ្លុះបញ្ចាំងឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ដោយ ថាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ គឺមិនសេរី និងមិនយុត្តិធម៌ទេ។

នៅក្នុងសេចក្តីថ្លែងការណ៍ ដែលបានផ្សាយនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ របស់គណបក្សកម្ពុជានិយម ក្រោយការប្រកាសលទ្ធផលបឋម នៃការបោះឆ្នោតឃុំ-សង្កាត់ ដោយបញ្ជាក់ថា ការបោះឆ្នោតឃុំ-សង្កាត់នេះ ពុំបានអនុវត្តពេញលេញតាមគោលការណ៍សេរី និងយុត្តិធម៌នោះទេ។[១៨] គណបក្សកម្ពុជានិយម សោកស្តាយចំពោះការប្រព្រឹត្តទៅនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥។ គណបក្សកម្ពុជានិយម បានរកឃើញពីភាពមិនប្រក្រតីមួយចំនួននៅមុនពេលបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ភាពមិនប្រក្រតីទាំងនោះមានដូចជា៖ ការបំពានដែនសមត្ថកិច្ចរបស់អាជ្ញាធរភូមិឃុំលើស្ថាប័នរៀបចំការបោះឆ្នោត ការគំរាមកំហែងដល់ប្រជាពលរដ្ឋ ដែលមានបំណងឈរឈ្មោះជាបេក្ខជន និងការមិនមានសិទ្ធិស្មើគ្នាក្នុងការអនុញ្ញាតឱ្យលើកស្លាកសញ្ញាគណបក្សជាដើម។ ក្រៅពីនេះ គណបក្សក៏រកឃើញដែរថា មានករណី យករថយន្តបិទសញ្ញាគណបក្សចូលក្នុងមណ្ឌលបោះឆ្នោត ការរាប់សន្លឹក ឆ្នោតពុំបានធ្វើជាចំហរ និងមានក្រុមអង្គុយចាំកាត់ឈ្មោះប្រជាពលរដ្ឋដែលទៅបោះឆ្នោតនៅជិត ឬនៅក្បែរមណ្ឌលបោះឆ្នោត។ គណបក្សកម្ពុជានិយម ដែលបង្កើតឡើងដោយក្រុមលោក យ៉ែម បុញ្ញឫទ្ធិ ក្រោយការរំលាយ គណបក្សសង្គ្រោះជាតិ ក៏បានអំពាវនាវឱ្យសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ទើបជាប់ឆ្នោតថ្មីទាំងអស់ បម្រើរាស្ត្រតាមមូលដ្ឋានឃុំសង្កាត់ ដោយស្អាតស្អំ មិនរើសអើង ដើម្បីយុត្តិធម៌សង្គម ប្រជាធិបតេយ្យ សេរីពហុបក្ស និងសិទ្ធិសេរីភាព ដើម្បីកម្ពុជាទាំងអស់គ្នា។[១៩]

---

[១៨] កម្ពុជាថ្មី, "គណបក្សចំនួន ៩ ប្រកាសថា ការបោះឆ្នោតឃុំ-សង្កាត់អាណត្តិនេះ ប្រព្រឹត្តទៅដោយល្អ និងទទួលយកលទ្ធផល", "sopheak khoun", "ថ្ងៃអង្គារ ៧ មិថុនា ២០២២", "https://www.kampucheathmey.com/politics/325012" ( accessed date 21-June-2022 at 10 AM)

[១៩] RFA, "គណបក្សកម្ពុជានិយមថា ការបោះឆ្នោតឃុំសង្កាត់ពុំបានអនុវត្តពេញលេញតាមគោលការណ៍សេរី និងយុត្តិធម៌នោះទេ", "សុជីវី", "2022.06.06", "https://www.rfa.org/khmer/news/politics/kampucheaniyum-party-says-commune-election-is-not-free-and-fair-06062022115037.html" ( accessed date 21-June-2022 at 10 PM)

ចំណែកគណបក្សប្រជាធិបតេយ្យមូលដ្ឋាន មិនបានថ្លែងចំៗថាមិនទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នេះទេ ក៏ប៉ុន្តែគណបក្សនេះបានវាយតម្លៃ ជាទូទៅថា ដំណើរការបោះឆ្នោតនៅឆ្នាំ២០២២នេះ វាអាក្រក់ជាងពេលណាៗទាំងអស់។ លោកបណ្ឌិត យង់ សាំងកុមារ ដែលជាប្រធានគណៈកម្មការនាយក គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ថ្លែងឱ្យដឹងថា គណបក្សរបស់លោកនឹងតស៊ូមតិ មិនអាចបណ្តោយឱ្យមានស្ថានភាពបែបនេះបន្តកើតមានទៀតទេ។ លោក នឹងបន្តការទាមទារឱ្យមានការកែលម្អរ សេរីភាពនយោបាយ ភាពស្មើភាពគ្នានៃការប្រកួតប្រជែង និងការលើកគុណតម្លៃដើម្បីភាពរីកចំរើននៃប្រទេសជាតិ គឺជា បញ្ហាសំខាន់ ដែលគណបក្សប្រជាធិបតេយ្យមូលដ្ឋានត្រូវបន្តធ្វើនៅថ្ងៃខាងមុខ។[២០] គណបក្សប្រជាធិបតេយ្យមូលដ្ឋាន កំពុងប្រមូលភាពមិនប្រក្រតី នៅក្នុងដំណើរការបោះឆ្នោត កាលពីថ្ងៃទី០៥ ខែមិថុនា កន្លងទៅ និងទាក់ទងជាមួយគណបក្សផ្សេងទៀត ដើម្បីរួមគ្នាតទល់ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ លោក ក៏បានបញ្ជាក់ផងដែរថា ការតទល់ជាមួយ គ.ជ.ប គឺក្នុងន័យឱ្យមានការកែប្រែឱ្យល្អ សម្រាប់ការបោះឆ្នោត ឆ្នាំ២០២៣ខាងមុខនេះ។ លោក បណ្ឌិត បញ្ជាក់បន្ថែមថា គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន ទទួលយក លទ្ធផលនៃការបោះឆ្នោតដោយការមិនពេញចិត្តឬទទួលយក ដោយភាពឈឺចាប់ ហើយការទទួលដោយភាពឈឺចាប់នេះ គឺមិនមែនដោយសារតែគណបក្សរបស់ លោកមិនបានកៅអីច្រើននោះទេ ប៉ុន្តែគណបក្សរបស់លោកចង់បានការប្រកួតប្រជែងមួយដោយសេរី និង ស្មើភាពគ្នា។[២១] នេះបើយោងតាមប្រសាសន៍របស់ លោក បណ្ឌិត យ៉ង សាំងកុមារ ក្នុងសន្និសីទកាសែតរបស់គណបក្ស នៅព្រឹកថ្ងៃទី០៧ ខែមិថុនា កន្លងទៅ។

រីឯគណបក្សភ្លើងទៀន បានចេញសេចក្តីថ្លែងការណ៍នៅថ្ងៃទី៦ ខែមិថុនា ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ មានបរិយាកាសមិនស្មើភាព ដោយសារពលរដ្ឋពុំមានសេរីភាពក្នុងការចូលរួមផ្នែកនយោបាយ និងការបញ្ចេញមតិ។ គណបក្សភ្លើងទៀន មើលឃើញថា មន្ត្រីស្ថាប័នបោះឆ្នោតពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមសុទ្ធសឹងជាមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជា។ បេក្ខជន និងអ្នកសង្កេតការណ៍របស់គណបក្សភ្លើងទៀនត្រូវទទួលរងការគាបសង្កត់ និងការបំភិតបំភ័យ។ ទន្ទឹមនឹងនេះ ក៏មានសកម្មភាពគៀងគពលរដ្ឋតាមរយៈការទិញសន្លឹកឆ្នោត ការតាមដាន ការសំឡុត ការគំរាមកំហែងជាហូរហែរដោយមិនមានការអង្កេត និងទប់ស្កាត់ពី គ.ជ.ប ឡើយ។ គណបក្សភ្លើងទៀនលើកឡើងថា នៅថ្ងៃបោះឆ្នោតស្ទើរគ្រប់មណ្ឌលបោះឆ្នោតទូទាំងប្រទេសបានបិទទ្វារចាក់សោរបេង ចាប់ពីម៉ោង៣រសៀលដោយបណ្តេញពលរដ្ឋចេញ មិនឱ្យតាមដានការរាប់សន្លឹកឆ្នោត និងបណ្តេញភ្នាក់ងារមកពីគណបក្សនយោបាយក្រៅរដ្ឋាភិបាលចេញពីការិយាល័យបោះឆ្នោតជាដើម ហើយករណីខ្លះ គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត មិនអនុញ្ញាតឱ្យថតលទ្ធផលបោះឆ្នោត ដែលបិទនៅការិយាល័យបោះឆ្នោតទៀតផង។ ផ្ទុយ

---

[២០] RFI, "បណ្ឌិត យង់ សាំងកុមារ៖ ការបោះឆ្នោតពេលនេះអាក្រក់ជាងពេលណាៗទាំងអស់", "07/06/2022", "https://rfi.my/8TuS" ( accessed date 21-June-2022 at 10 AM)

[២១] RFI, "បក្សប្រជាធិបតេយ្យមូលដ្ឋានគ្រោងជួបបក្សផ្សេងទៀត ដើម្បីតទល់ជាមួយ គ.ជ.ប", "07/06/2022", "https://rfi.my/8Tqj" ( accessed date 21-June-2022 at 10 AM)

ទៅវិញអាជ្ញាធរមូលដ្ឋាន និងតំណាងអង្គការសង្កេតការណ៍ របស់បក្សកាន់អំណាច មានសិទ្ធិនៅក្នុងបរិវេនទីតាំងទាំងនោះដោយសេរី។ គណបក្សភ្លើងទៀន ចាត់ទុកការរំលោភបំពានទាំងនេះ រួមទាំងករណីរំលោភបំពានជាច្រើនទៀតថា បង្ហាញពីសកម្មភាពនៃការលួចសន្លឹកឆ្នោត។ អនុប្រធានគណបក្សភ្លើងទៀនលោក សុន ឆ័យ បានចាត់ទុកការបោះឆ្នោតថ្នាក់ឃុំ សង្កាត់នេះថា មិនប្រព្រឹត្តដោយសេរីត្រឹមត្រូវ និងយុត្តិធម៌នោះទេ ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនឯករាជ្យ និងហាក់លម្អៀងទៅរកគណបក្សកាន់អំណាច ខណៈអាជ្ញាធរមិនអព្យាក្រិត្យ។ លោកថា ជំហររបស់គណបក្ស មិនធ្វើបាតុកម្មប្រឆាំងលទ្ធផលបោះឆ្នោតដូចលើកមុនៗនោះទេ។ លោករំពឹងថា លទ្ធផលបោះឆ្នោតនេះនឹងបើកផ្លូវចរចាជាមួយគណបក្សកាន់អំណាច ដើម្បីឈានដោះស្រាយបញ្ហានយោបាយ និងកែលម្អស្ថានប័នបោះឆ្នោតឱ្យល្អប្រសើរឡើងវិញ៖ «យើងប្រកាសនៅថ្ងៃនេះថាយើងអត់មានផែនការធ្វើបាតុកម្មទេ ប៉ុន្តែយើងត្រូវលើកឡើងនូវបញ្ហា កង្វល់របស់យើង ឬកង្វល់របស់ពលរដ្ឋម្ចាស់ឆ្នោតដែរ ពីភាពមិនប្រកតីដែលប៉ះពាល់ដល់ឆន្ទៈរបស់លោក ហើយយើងសូមឱ្យមានការកែលម្អ ដូច្នេះគណបក្សភ្លើងមានជំហរចង់ដោះស្រាយ និងជជែកគ្នា»។ គណបក្សភ្លើងទៀន ក៏បានប្រកាសទទួលយកលទ្ធផលបោះឆ្នោតនេះ បើទោះបីជាការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នេះ ប្រព្រឹត្តទៅមិនមានសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីស្វែងរកការចរចាជាមួយបក្សកាន់អំណាច។ មូលហេតុដែលគណបក្សភ្លើងទៀនព្រមទទួលលទ្ធផលមិនមែនមានន័យថាគណបក្សនេះយល់ស្របថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើឡើងត្រឹមត្រូវ និងយុត្តិធម៌នោះទេ។[២២] ផ្ទុយទៅវិញ មកពីគណបក្សភ្លើងទៀនចង់ជួបចរចាជាមួយគណបក្សកាន់អំណាចដើម្បីជំរុញឱ្យមានដំណោះស្រាយបញ្ហាប្រទេសជាតិ និងកែទម្រង់ប្រព័ន្ធបោះឆ្នោតនៅកម្ពុជាឱ្យមានភាពឯករាជ្យ តែប៉ុណ្ណោះ។ លោកបន្តថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលហៅកាត់ថា គ.ជ.ប បច្ចុប្បន្នមិនឯករាជ្យ ហើយបានជួយដល់គណបក្សប្រជាជនកម្ពុជាច្រើន អំឡុងពេលបោះឆ្នោតអាណត្តិនេះ។ លោក សុន ឆ័យ បញ្ជាក់ទៀតថា គណបក្សភ្លើងទៀនបានរងគ្រោះ និងរងការចោទប្រកាន់ពីសំណាក់មនុស្សមួយចំនួនដែលថា ការចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ របស់បក្សភ្លើងទៀននេះ ដើម្បីធ្វើឱ្យគណបក្សកាន់អំណាចហ៊ឺហា និងបំពេញភាពស្របច្បាប់គណបក្សកាន់អំណាច។ ដោយរងគ្រោះច្រើនបែបនេះ លោកបង្ហាញក្តីសង្ឃឹមថា គណបក្សកាន់អំណាចអាចងាយមកចរចាជាមួយបក្សភ្លើងទៀន ដោយហេតុថា បើសិនជាបក្សកាន់អំណាចចរចានឹងទទួលបានផលប្រយោជន៍ច្រើន

[២២] RFA, "គណបក្សភ្លើងទៀនប្រកាសមិនទទួលស្គាល់លទ្ធផលបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥", "មាន ឫទ្ធ", "2022.06.06", "https://www.rfa.org/khmer/news/politics/candlelight-party-considers-election-results-no-reflect-will-of-the-people-and-vote-fraud-06062022094410.html" ( accessed date 21-June-2022 at 10 PM)

ជាពិសេសការរក្សាប្រព័ន្ធអនុគ្រោះពន្ធ EBA ពីសហភាពអឺរ៉ុប។[២៣] កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ សហភាពអឺរ៉ុប ប្រកាសដកប្រព័ន្ធអនុគ្រោះទាំងស្រុងចេញពីប្រទេសកម្ពុជា បើសិនជាខ្លួនរកឃើញថាការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់នៅកម្ពុជាប្រព្រឹត្តទៅមិនសេរី ត្រឹមត្រូវ និងយុត្តិធម៌នោះទេ។

ជុំវិញលទ្ធផលឆ្នោតនេះដែរ លោក អ៊ូ ចាន់រ័ត្ន សហស្ថាបនិក គណបក្សកែទម្រង់កម្ពុជា បានចាត់ទុកថា គ.ជ.ប នៅមិនទាន់មានតម្លាភាព និងឯករាជ្យ ដោយស្ថាប័នមួយនេះបន្តលំអៀងទៅកាន់ បក្សកាន់អំណាចដដែល។ លោក អ៊ូ ចាន់រ័ត្នបន្តថា ប្រសិនបើ គ.ជ.ប នៅតែបន្តអនុវត្តទម្លាប់បែបនេះ នោះប្រទេសកម្ពុជានឹងក្លាយជាប្រទេសកុម្មុនីស្ត រឺឯកបក្សនាពេលឆាប់ៗជាមិនខាន។

លោក ញឿន រ៉ាដែន អ្នកនាំពាក្យ គណបក្សហ៊្វុនស៊ិនប៉ិចឯណោះ ក៏បានបញ្ជាក់ដែរថា គណបក្សហ៊្វុនស៊ិនប៉ិចនៅមិនទាន់សម្រេចថា នឹងទទួលយកលទ្ធផលឆ្នោតមួយនេះបាននៅឡើយ ព្រោះសម្លេងឆ្នោតនៅតាមឃុំសង្កាត់មួយចំនួនមានភាពមិនប្រក្រតី។

បើតាមលិខិតរបស់សម្តេច ស ខេង អនុប្រធានគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២២ លើកឡើងថា ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិ ទី៥ បានប្រព្រឹត្តទៅដោយជោគជ័យ ក្រោមបរិយាកាសស្ងប់ស្ងាត់ សុខសន្តិភាព និងគ្មានអំពើហិង្សា។ សម្តេច ស ខេង បន្តថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥នេះ បានបង្ហាញទៅកាន់ មជ្ឈដ្ឋានជាតិនិងអន្តរជាតិ ឱ្យឃើញនូវភាពកាន់តែចាស់ទុំ និងភាពម្ចាស់ការរបស់គណបក្ស នយោបាយនៅកម្ពុជា។ ទន្ទឹមនឹងនេះ ក៏បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត របស់គណបក្សប្រជាជន កម្ពុជាក្នុងការអនុវត្តគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ស្របតាមរដ្ឋធម្មនុញ្ញនៃកម្ពុជា។[២៤]

ជាមួយគ្នានេះ គណបក្សខ្មែររួបរួមជាតិរបស់លោក ញឹក ប៊ុនឆៃ បានចេញសេចក្តីថ្លែងការណ៍មួយដោយប្រកាសថា ការបោះឆ្នោតនេះដំណើរការទៅប្រកបដោយលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងគ្មានការបង្ខិតបង្ខំឡើយ។ បើតាមគណបក្សខ្មែររួបរួមជាតិ ក្នុងពេលបោះឆ្នោតនេះ មានបរិយាកាស

---

[២៣] ដឺ ខែមបូឌា ដេលី, "បក្សភ្លើងទៀនប្រកាសទទួលលទ្ធផលបោះឆ្នោតដើម្បីស្វែងរកការចរចាជាមួយបក្សកាន់អំណាច", "ដឺ ខែមបូឌា ដេលី", "June 7, 2022", "https://www.cambodiadaily.com/2022/06/07/14/23/62668/" ( accessed date 21-June-2022 at 10 AM)

[២៤] Fresh News, "សម្តេចក្រឡាហោម ស ខេង ថ្លែងអំណរគុណក្រុមការងារ និងថ្នាក់ដឹកនាំគណបក្សគ្រប់លំដាប់ថ្នាក់ នៃខេត្តព្រៃវែង ដែលខិតខំអស់កម្លាំងកាយ និងស្មារតី ដណ្តើមជោគជ័យជូនបក្ស»", "2022-06-06", "http://m.freshnewsasia.com/index.php/en/localnews/245050-2022-06-06-06-36-21.html" ( accessed date 21-June-2022 at 10 AM)

ស្ងប់ស្ងាត់ល្អ និងដំណើរការទៅដោយរលូន គ្មានឧបសគ្គ និងគ្មានអំពើហិង្សា។ គណបក្សរបស់លោក ញឹក ប៊ុនឆៃ ថា ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោតនេះ គឺអាចទទួលយកបាន។[២៥]

គណបក្សខ្មែរស្រលាញ់ជាតិ ដែលបង្កើតឡើងដោយក្រុមលោក ជីវ កត្តា អតីតតំណាងរាស្ត្រនៃអតីតគណបក្សសង្គ្រោះជាតិ ហើយបានចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៥នេះដែរ បានចេញសេចក្តីថ្លែងការណ៍មួយដោយបញ្ជាក់ថា ដំណើរការបោះឆ្នោតមានភាពល្អប្រសើរ ទាំងមន្ត្រីរៀបចំការបោះឆ្នោត និងសកម្មជនគណបក្ស ក៏ដូចជាប្រជាពលរដ្ឋម្ចាស់ឆ្នោត មានភាពចាស់ទុំជាងអាណត្តិមុនៗ។ គណបក្សខ្មែរស្រលាញ់ជាតិ បញ្ជាក់បន្ថែមថា ខ្លួននឹងគោរពតាមច្បាប់ បទបញ្ជា នីតិវិធី និងឆន្ទៈរបស់ប្រជាពលរដ្ឋ ក្រោយការបោះឆ្នោតនេះ។[២៦]

ចំណែកគណបក្សខ្មែរតែមួយ បានសង្កេតឃើញថា បរិយាកាសនៅក្នុងអំឡុងពេលធ្វើយុទ្ធការឃោសនារកសម្លេងឆ្នោត ចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ និងការបោះឆ្នោតនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅថ្មីៗនេះ គឺមានភាពល្អប្រសើរ ដោយសារគ្រប់ភាគី ពាក់ព័ន្ធមានភាពចាស់ទុំខាងនយោបាយ ធ្វើឱ្យមានភាពរលូន គ្មានការរំខាន និងគ្មានអំពើ ហិង្សាណាមួយបានកើតឡើងនោះទេ។[២៧]

រីឯគណបក្សឯកភាពជាតិខ្មែរ បានប្រកាសគាំទ្រ និងទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ បើទោះបីជាគណបក្សមួយនេះ មិនទទួលបានអាសនៈក៏ដោយ។ គណបក្សឯកភាពជាតិខ្មែរ ក៏បានបង្ហាញក្តីសង្ឃឹមថា គ្រប់គណបក្សនយោបាយ ដែលទទួលបានក្រុម

---

[២៥] Fresh News, "គណបក្សខ្មែររួបរួមជាតិ៖ ការបោះឆ្នោតឃុំសង្កាត់ ដំណើរការប្រកបដោយលទ្ធិប្រជាធិបតេយ្យ សេរី ហើយលទ្ធផលអាចទទួលយកបាន»", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245052-2022-06-06-07-15-12.html" (accessed date 21-June-2022 at 10 AM)

[២៦] កម្ពុជាថ្មី, គណបក្សចំនួន ៩ ប្រកាសថា ការបោះឆ្នោតឃុំ-សង្កាត់អាណត្តិនេះ ប្រព្រឹត្តទៅដោយល្អ និងទទួលយកលទ្ធផល", "sopheak khoun", "ថ្ងៃអង្គារ ៧ មិថុនា ២០២២", "https://www.kampucheathmey.com/politics/325012" (accessed date 21-June-2022 at 10 AM)

[២៧] Fresh News, "គណបក្សខ្មែរតែមួយ ចេញសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ មានភាពរលូន គ្មានការរំខាន និងគ្មានអំពើហិង្សា»", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245033-2022-06-06-03-58-32.html" (accessed date 21-June-2022 at 10 AM)

ប្រឹក្សាឃុំ-សង្កាត់ នឹងបម្រើពលរដ្ឋដោយយកចិត្តទុកដាក់ អភិវឌ្ឍន៍ឃុំ-សង្កាត់ អនុវត្តច្បាប់ និងផ្ដល់សិទ្ធិសេរីភាពដល់ពលរដ្ឋ តាមច្បាប់ជាធរមាន។[២៨]

សម្រាប់ប្រធានគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ លោក ម៉ម សូណង់ដូ ចាត់ទុកការបោះឆ្នោត កាលពីថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០២២ កន្លងទៅនេះ បានប្រព្រឹត្តទៅក្នុងទិដ្ឋភាពដ៏ឱឡារិក និងប្រកបទៅដោយភាពស្ងប់ស្ងាត់គួរឱ្យកត់សម្គាល់ ទោះបីជាមានលទ្ធផលក្នុងរូបភាពណាក៏ដោយ។

ដូចគ្នានេះដែរ គណបក្សសញ្ញាតិកម្ពុជា ក៏បានបញ្ជាក់ថា ការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៥ មានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានរូបភាព គំរាមកំហែងទេ។ នៅក្នុងនោះ ដំណើរការនៃការបោះឆ្នោត គឺបានប្រព្រឹត្តិទៅដោយរលូន ក្នុងស្ថាន ភាពសន្តិសុខ និងសណ្ដាប់ធ្នាប់ល្អ ជាពិសេសប្រជាពលរដ្ឋ បានចេញទៅបោះឆ្នោតយ៉ាងច្រើនកុះករ មានទៅដល់ជាង ៨០% នៃចំនួនអ្នកបោះឆ្នោតសរុប។[២៩]

គណបក្សយុវជនកម្ពុជា បានចេញមកអះអាងតាមរយៈ សេចក្ដីការណ៍ថា ដំណើរការ បោះឆ្នោតឃុំសង្កាត់អាណត្តិទី៥នេះ ធ្វើឡើងដោយរលូន មានសណ្ដាប់ធ្នាប់ សន្តិសុខ សេរីភាព យុត្តិធម៌ តម្លាភាព និងគ្មានរូបភាពគំរាមកំហែង ណាមួយកើត ឡើងនោះទេ។ ជាពិសេស គណបក្សទាំងពីរបន្តថា គជបបានរៀបចំឡើងដោយឯករាជ្យ និងស្របតាម លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងទទួលយកបាន។[៣០]

រីឯ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា បានលើកឡើងកាលពីថ្ងៃទី៦ ខែមិថុនា ថា៖ «ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំ ប្រឹងប្រែង និងការយកចិត្តទុកដាក់ បំពេញភារ កិច្ចប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ ពីសំណាក់អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធ ទាំងអស់ក្នុងការចូលរួម»។ លោកបន្តថា៖ «ដោយឈរលើគោលការណ៍ អព្យាក្រឹត ក្នុងវិជ្ជាជីវៈ ដែលបានបង្ក

---

[២៨] Fresh News, "គណបក្សឯកភាពជាតិខ្មែរ ចេញសេចក្ដីថ្លែងការណ៍ គាំទ្រនិងទទួលយកលទ្ធផលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៥»", "2022-06-07", "http://www.freshnewsasia.com/index.php/en/localnews/245120-2022-06-07-03-06-18.html" ( accessed date 21-June-2022 at 10 AM)

[២៩] Fresh News, "គណបក្សសញ្ញាតិកម្ពុជា សេចក្ដីថ្លែងការណ៍ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥នេះ ល្អប្រសើរច្រើនជាងអាណត្តិមុនៗ»", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245045-2022-06-06-06-05-43.html" ( accessed date 21-June-2022 at 10 AM)

[៣០] RFI, "គណបក្សមួយចំនួនចាត់ទុកការបោះឆ្នោតឃុំសង្កាត់អាណត្តិទី៥ មិនយុត្តិធម៌ និងសេរីភាព", "06/06/2022", "https://rfi.my/8TgL" ( accessed date 25-June-2022 at 10 AM)

លក្ខខណ្ឌអំណោយផល និងបរិយាកាស សន្តិសុខល្អប្រសើរសម្រាប់ប្រជាពលរដ្ឋ និង បណ្តាគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត អាចអនុវត្តសិទ្ធិសេរីភាព ស្របតាមឆន្ទៈរបស់ខ្លួន»។ លោកបន្ថែមថា៖ «ដំណើរការប្រព្រឹត្តទៅដោយជោគជ័យ ក្រោមបរិយាកាសស្ងប់ស្ងាត់ សុខសន្តិភាព និងគ្មាន អំពើហិង្សា នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ក៏បានបង្ហាញទៅកាន់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ឱ្យឃើញនូវភាពកាន់តែចាស់ទុំ និងភាពម្ចាស់ការ ព្រមទាំងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការអនុវត្តគោលការណ៍នៃ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃនៅកម្ពុជា»។[៣១]

ជារួម យើងសង្កេតឃើញថា ទាំងគណបក្សដែលទទួលបានអាសនៈ និងមិនទទួលបានអាសនៈ។ ទាំងគណបក្សដែលមាននិន្នាការទៅរកគណបក្សប្រឆាំង ទាំងគណបក្សដែលមាននិន្នាការទៅរក រដ្ឋាភិបាល សុទ្ធតែបានទទួលយកលទ្ធផលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប ដែលនេះបានបង្ហាញទៅកាន់ មជ្ឈដ្ឋានជាតិនិងអន្តរជាតិ ឱ្យឃើញនូវភាពកាន់តែចាស់ទុំ និងភាពម្ចាស់ ការរបស់គណបក្សនយោបាយ និងគណកម្មការជាតិរៀបចំការបោះឆនោតនៅកម្ពុជា (គ.ជ.ប) បើទោះ បីជាមានគណបក្សមួយចំនួន ដែលមាននិន្នាការទៅរកបក្សប្រឆាំងមួយចំនួន បាននៅបន្តទាមទារ ឱ្យមានការធ្វើកំណែទម្រង់ គ.ជ.ប បន្ថែមទៀត ដោយចាត់ទុកថា ស្ថាប័នមួយនេះ នៅមិនទាន់ឯករាជ្យ និងហាក់លម្អៀងទៅរកគណបក្សកាន់អំណាច។

## ៤. ២. អង្គការជាតិ អន្តរជាតិ និងសង្គមស៊ីវិល

អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ មកពី៧៥អង្គភាព ដែលមកពីបណ្តាប្រទេសមួយចំនួន ដូចជា ចិន ម៉ាឡេស៊ី និងហ្វីលីពីន ជាដើម បានចាត់ទុកការបោះឆ្នោត ឃុំ-សង្កាត់ អាណត្តិទី៥ នេះថាមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព ដែលជាការបញ្ជាក់ពីការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជានាពេលបច្ចុប្បន្ន។ ចំណែកសម្រាប់ក្រុមអង្គការសង្គមស៊ីវិលនៅក្នុងប្រទេស បានកត់សម្គាល់ពីបញ្ហាបំភិតបំភ័យ សិទ្ធិរបស់ពលរដ្ឋ ដែលកើតមាន នៅតាមការិយាល័យនាអំឡុងពេលបោះឆ្នោត និងបានចាត់ទុកថា ការបោះឆ្នោតពេលនេះ មិនមានប្រជាធិបតេយ្យ ដ្បិតមានការគាបសង្កត់លើ សិទ្ធិសេរីភាពពលរដ្ឋ។

សមាគមពលរដ្ឋខ្មែរនៅប្រទេសអូស្រ្តាលី និងនូវ៉ែលហ្សេឡង់ចំនួន៦ ដែលបានបញ្ជូនតំណាងរបស់ខ្លួនចូលរួមសង្កេតការណ៍លើដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ បានវាយតម្លៃថា «ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥

---

[៣១] Khmer Times. "អ្នកសង្កេតការណ៍ថាការបោះឆ្នោតមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព", "Soth Koemsoeun", "June 7, 2022", "https://www.khmertimeskh.com/501089774/អនកសងកតករណថក/?p=1089774" (accessed date 25-June-2022 at 10 AM)

នៅព្រះរាជាណាចក្រកម្ពុជា ជាគំរូសម្រាប់ប្រទេសក្នុងតំបន់»។ សេចក្ដីថ្លែងការណ៍បាន បញ្ជាក់ថា «ប្រហែលជាគ្មានការបោះឆ្នោតទៀងត្រង់បំផុតដូចការបោះ ឆ្នោតនៅកម្ពុជា ដែលមាន ភាពត្រឹមត្រូវ គ្មានការលាក់លៀម គ្មានការកេងបន្លំ ព្រោះជាការ បោះឆ្នោតដែល មានការសង្កេតការណ៍ ពីភ្នាក់ងារគណបក្សនយោបាយ នៅតាមការិយាល័យបោះឆ្នោត ហើយការ រាប់សន្លឹកឆ្នោតទៀតសោត គឺធ្វើនៅការិយាល័យផ្ទាល់តែម្ដង បានន័យថាព័ត៌មានបានមក ស្ដែងចេញ លទ្ធផលឃើញទាំងអស់គ្នា គ្មានអ្នកណាបន្លំកើតទេ ហើយដល់លទ្ធផលបានមកឃើញ ទាំងអស់គ្នា»។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ពិតជាបានឆ្លុះបញ្ចាំងពីដំណើរការបោះឆ្នោត ដែល មានលក្ខណៈសេរី និងយុត្តិធម៌។ គណបក្សនយោបាយទាំងអស់ អាចចូលរួមដោយសេរី និងស្មើភាព ក្នុងគ្រប់ដំណើរការ និងស្របតាមក្របខណ្ឌច្បាប់។ ប្រជាពលរដ្ឋដែលបានចូលរួមបោះឆ្នោត មានការសាទរ និង បង្ហាញនូវឆន្ទៈរបស់ពួកគាត់ តាមរយៈការបោះឆ្នោតដោយសេរី និងសន្តិវិធី។ យើងខ្ញុំពុំឃើញ មានសញ្ញានៃការបំភ្លិតបំភ័យ និងអំពើហិង្សាណាមួយ នៅគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ ដែលយើងបានសង្កេត ក្នុងកំឡុងពេលនៃការបោះឆ្នោតនេះ។ ហើយអ្នកបោះឆ្នោត អាចចូលរួមបោះឆ្នោត ដោយសេរី និងសោមនស្សរីករាយក្នុងការជ្រើសរើសមេដឹកនាំឃុំ-សង្កាត់រៀងៗខ្លួន។[៣២]

អង្គការសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព (International Parliament for Tolerance and Peace-IPTP ដែលចូលរួមជាអ្នកសង្កេតការណ៍អន្តរជាតិ បានចេញសេចក្ដីថ្លែងការណ៍មួយ ដោយវាយតម្លៃថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ នៅកម្ពុជាពុំមានការគំរាមកំហែង គាបសង្កត់ និងអំពើហិង្សាឡើយ។ តាមរយៈសេចក្ដីថ្លែងការណ៍ដែលយើងទទួលបាន នៅថ្ងៃទី០៧ ខែមិថុនានេះ បានបញ្ជាក់ឱ្យដឹងថា នៅថ្ងៃបោះឆ្នោត ដែលត្រូវនឹងថ្ងៃទី៥ ខែ មិថុនា ឆ្នាំ ២០២២ គណៈប្រតិភូ អង្គការ IPTP បានធ្វើទស្សនកិច្ចនៅការិយាល័យបោះឆ្នោតមួយចំនួនក្នុងរាជធានីភ្នំពេញ។ យើងមានការចាប់ អារម្មណ៍ចំពោះចំនួនអ្នកចូលរួមបោះឆ្នោតដ៏ច្រើន ហើយយើងសង្កេតឃើញថា ប្រជាពលរដ្ឋបានចេញ មកបោះឆ្នោតដោយសេរី និងសម្ងាត់។ អង្គការសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព បានបន្ថែមថា សំខាន់ជាងនេះទៅទៀត អ្នកបោះឆ្នោតហាក់ដូចជាមានអារម្មណ៍រំភើបនិងសប្បាយរីករាយ ក្នុងការចូលរួមក្នុងដំណើរការបោះឆ្នោតនេះ ។ យើងសង្កេតឃើញថាពុំមានសញ្ញានៃការគំរាមកំហែង ការគាបសង្កត់ និងអំពើហិង្សាណាមួយឡើយ។ ក្រៅពីនេះ បុគ្គលិកបោះឆ្នោត ត្រូវបានជ្រើសរើសតាម រយៈដំណើរការមួយដែលមានតម្លាភាពនិងភាពប្រកួតប្រជែង ហើយពួកគេបានបំពេញការងារប្រកប ដោយសុចរិតភាព និងវិជ្ជាជីវៈ។ អង្គការសភាអន្តរជាតិ

[៣២] កោះសន្តិភាព, "សមាគមពលរដ្ឋខ្មែរ នៅប្រទេសអូស្ត្រាលី និងនូវ៉ែលហ្សេឡង់ ប្រកាសថា ដំណើរការនៃការបោះឆ្នោតឃុំ-សង្កាត់ ជាគំរូ សម្រាប់ប្រទេសក្នុងតំបន់", "០៧ ខែ មិថុនា ឆ្នាំ ២០២២", "https://kohsantepheapdaily.com.kh/article/1543328.html" ( accessed date 25-June-2022 at 10 AM)

ដើម្បីភាពអត់ឱន និងសន្តិភាព បានបញ្ជាក់ បន្ថែមថា ជាការពិតណាស់ យើងខ្ញុំសង្កេតឃើញថា គ.ជ.ប បានអនុវត្តតាមនីតិវិធីជាច្រើន ស្របតាម គោលការណ៍ណែនាំអន្តរជាតិ។ យ៉ាងណាមិញ យើងខ្ញុំសូមជូនយោបល់ទៅ គ.ជ.ប ថាគួរផ្តល់ការបណ្តុះ បណ្តាលបន្ថែមដល់មន្ត្រីនៅការិយាល័យ បោះឆ្នោតដោយផ្តែកការបង្ហាត់បង្ហាញ និងការអនុវត្តផ្ទាល់ គួរផ្តល់ភាពងាយស្រួលដល់ជនពិការ និងអ្នកដែលត្រូវការជំនួយជាពិសេស ក៏ដូចជាការបង្ហាញបញ្ជីឈ្មោះ អ្នកបោះឆ្នោតនៅលើជញ្ជាំង ឬក្តារនៅការិយាល័យ បោះឆ្នោត។[៣៣]

សេចក្តីថ្លែងការណ៍របស់អង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាល អាស៊ីប៉ាស៊ីហ្វិកអន្តរជាតិ (CAPDI) បានលើកឡើងថា "បរិយាកាសនៃការបោះឆ្នោតទាំងមូលត្រូវបានកំណត់ថា មានភាពស្ងប់ស្ងាត់ សន្តិភាព និងអហិង្សា។ CAPDI សម្តែងអបអរសាទរចំពោះប្រជាជនកម្ពុជា ដែលបានចូលរួមយ៉ាងសកម្មក្នុង ការបោះឆ្នោត"។ គណៈប្រតិភូបានកត់សម្គាល់ឃើញថា អត្រាអ្នកទៅបោះឆ្នោតមានភាពល្អប្រសើរ ហើយបុគ្គលិក គ.ជ.ប ក៏បានធ្វើការដោយភាពត្រឹមត្រូវ និងភាពស្មោះត្រង់ផងដែរ។ «បរិយាកាសនៃ ការបោះឆ្នោតទាំងមូលត្រូវបានកំណត់ថា មានភាពស្ងប់ស្ងាត់ សន្តិភាព និងអហិង្សា។ គណៈប្រតិភូមិន បានសង្កេតឃើញមានការតវ៉ាណាមួយ ដែលអាចប៉ះពាល់ដល់ដំណើរការ ឬលទ្ធផលនៃការបោះឆ្នោត ឆ្នាំ២០២២នោះទេ»។ អង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអាស៊ីប៉ាស៊ីហ្វិកអន្តរជាតិ (CAPDI) ក៏បានសម្តែងអបអរសាទរចំពោះប្រជាជនកម្ពុជា ដែលបានចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត ហើយ សូមជូនពរឱ្យប្រទេសកម្ពុជា ទទួលបានជោគជ័យគ្រប់បែបយ៉ាងក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការ អភិវឌ្ឍន៍របស់ខ្លួន។ ជោគជ័យនៃការបោះឆ្នោតឆ្នាំ២០២២ គឺជាជំហានដ៏សំខាន់មួយទៀតក្នុងការជំរុញ កំណែទម្រង់ដែលកំពុងបន្តរបស់ព្រះរាជាណាចក្រ ដើម្បីសម្រេចបាននូវសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋ ចំពោះសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍។[៣៤]

---

[៣៣] ខ្មែរប៉ុស្ដិ៍, ‶អង្គការសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព សង្កេតឃើញថា ការបោះឆ្នោតនៅកម្ពុជាពុំមានការគំរាមកំហែង គាបសង្កត់ និងអំពើហិង្សាឡើយ″, ‶ថ្ងៃអង្គារ ទី៧ ខែមិថុនា ឆ្នាំ២០២២″, ‶លី វិទ្យា″, ‶https://khmerpostasia.com/archives/89805″ (accessed date 25-June-2022 at 10 AM)

[៣៤] Fresh News, ‶ក្រុមអ្នកប្រជាធិបតេយ្យនិយមកណ្តាល ដែលចូលរួមជាអ្នកសង្កេតការណ៍អន្តរជាតិ វាយតម្លៃថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅកម្ពុជា មានភាពស្ងប់ស្ងាត់ សន្តិភាព និងអហិង្សា″, ‶2022-06-06″, ‶http://www.freshnewsasia.com/index.php/en/localnews/245034-2022-06-06-04-27-23.html″ (accessed date 25-June-2022 at 10 AM)

អ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យ បានចេញសេចក្តីថ្លែងការណ៍របស់ខ្លួន ដោយបានបញ្ជាក់ថា "ការបោះឆ្នោតនៅ កម្ពុជាបានប្រព្រឹត្តិទៅប្រកបដោយសមធម៌ទៅតាមក្បួនច្បាប់អន្តរជាតិ ស្ថិតក្នុង បរិយាកាសស្ងប់ស្ងាត់ តម្លាភាព និងសេរីភាព"។[៣៥]

សមាគមខ្មែរចំនួន៣ ដែលមានមូលដ្ឋាននៅប្រទេសកូរ៉េខាងត្បូង បានចេញសារគាំទ្រដំណើរការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៥ ដោយការមើលឃើញថា ការបោះឆ្នោត នេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា។ សមាគមគូសបញ្ជាក់ថា «យើងខ្ញុំសូមវាយតម្លៃខ្ពស់ថា ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់ សន្លឹកឆ្នោត និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលស្វែងរកឈ្មោះ និងការិយាល័យបោះឆ្នោត រួមទាំងការ ចូលរួមយ៉ាងសកម្មរបស់ក្រុមអ្នកសង្កេតការណ៍ភ្នាក់ងារបក្សនយោបាយ ភ្នាក់ងារជាតិ និងអន្តរជាតិ គឺប្រព្រឹត្តទៅយ៉ាងរលូន សេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា»។[៣៦]

សហភាពសហព័ន្ធយុវជនកម្ពុជា ដែលបានបញ្ជូនសមាជិក សមាជិការបស់ខ្លួនប្រមាណជិត ៤ម៉ឺននាក់ ចូលរួមសង្កេតការណ៍ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ ២០២២ បានចេញសេចក្តីថ្លែងការណ៍ជុំវិញដំណើរការបោះឆ្នោតមួយនេះ។ សហភាពសហព័ន្ធយុវជន កម្ពុជា សូមសម្តែងនូវការអបអរសាទរ និងកោតសរសើរចំពោះកិច្ចខិតខំ ប្រឹងប្រែងបំពេញតួនាទី និងភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំង អាជ្ញា ធរពាក់ព័ន្ធ និងមន្ត្រីនៃគណៈកម្មាធិការរៀបចំការបោះឆ្នោតនៅគ្រប់កម្រិត គ្រប់លំដាប់ថ្នាក់ ដែលបានធានាឱ្យការបោះឆ្នោតនេះ ប្រព្រឹត្តទៅក្នុងបរិយាកាសល្អប្រសើរ គ្មានការបង្ខិតបង្ខំ គ្មានការ គំរាមកំហែង និងគ្មានអំពើហិង្សា ពិសេសបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីភាពសេរី ភាពត្រឹមត្រូវ និងយុត្តិធម៌នៃការបោះឆ្នោត ព្រមទាំងតម្លាភាព ភាពចាស់ទុំ និងភាពឯករាជ្យម្ចាស់ការ ក្នុងការរៀបចំការ បោះឆ្នោតនៅកម្ពុជា ដែលជាគ្រឹះដ៏រឹងមាំនៃកិច្ចដំណើរការប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ។ សហភាពសហព័ន្ធយុវជនកម្ពុជា ក៏សូមសម្តែងនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះសមាជិក សមាជិកា នៃសហភាពសហព័ន្ធយុវជនកម្ពុជា ដែលបានចូលរួម

---

[៣៥] Khmer Times, "អ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យនិយាយថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់របស់ កម្ពុជាបានប្រព្រឹត្តទៅតាមក្បួនច្បាប់អន្តរជាតិ", "June 7, 2022", "https://www.khmertimeskh.com/501089566/អនកសងកតករណអនតរ/" (accessed date 25-June-2022 at 10 AM)

[៣៦] Fresh News, "សមាគមខ្មែរនៅកូរ៉េខាងត្បូង ប្រកាសគាំទ្រដំណើរការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នៅកម្ពុជា", "2022-06-08", "http://www.freshnewsasia.com/index.php/en/localnews/245314-2022-06-08-14-12-54.html" (accessed date 25-June-2022 at 10 AM)

យ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ ឱ្យទទួលបានលទ្ធផលជោគជ័យ។[៣៧]

សម្ព័ន្ធយុវជនស្រលាញ់សន្តិភាព ដែលបានបញ្ជូនអ្នកសង្កេតការណ៍ទូទាំងប្រទេសចំនួន ២,៦២៤រូប ទៅសង្កេតការណ៍តាមបណ្តាការិយាល័យនានា នៅទូទាំង២៥រាជធានី-ខេត្ត នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២នេះ បានចេញសេចក្តីថ្លែងការណ៍បញ្ជាក់ថា ការដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ប្រព្រឹត្តដោយរលូន សេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព។[៣៨]

សហព័ន្ធនិស្សិត បញ្ញាវ័ន្ត ប្រជាធិបតេយ្យកម្ពុជា ចេញសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។[៣៩]

អង្គការមូលនិធិអភិវឌ្ឍន៍និស្សិតឥស្លាម បានវាយតម្លៃថា ការបោះឆ្នោតជ្រើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គឺបានប្រព្រឹត្តទៅក្នុងបរិយាកាសសេរី យុត្តិធម៌ និងតម្លាភាព ក្នុងលំហសិទ្ធិសេរីភាពពេញលេញ។[៤០]

អ្នកសង្កេតការណ៍ជនជាតិកូរ៉េខាងត្បូង៖ ប្រជាធិបតេយ្យកូរ៉េខាងត្បូង និងកម្ពុជា មានលក្ខណៈស្រដៀងគ្នា។ ក្រោយបានចូលរួមសង្កេតការណ៍នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ របស់កម្ពុជារួចមក លោក យុន យ៉ុង ហូ (Yun Young Ho) អគ្គនាយក នៃអង្គការ

---

[៣៧] Fresh News, "ស.ស.យ.ក ចេញសេចក្តីថ្លែងការណ៍ ជុំវិញដំណើរបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ដែលប្រព្រឹត្តទៅដោយតម្លាភាព និងត្រឹមត្រូវតាមច្បាប់", "2022-06-12", "http://www.freshnewsasia.com/index.php/en/localnews/245605-2022-06-12-02-53-25.html" (accessed date 25-June-2022 at 10 AM)

[៣៨] Fresh News, "សម្ពន្ធយុវជនស្រលាញ់សន្តិភាព ចេញសេចក្តីថ្លែងការណ៍ថា ការដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ប្រព្រឹត្តដោយរលូន សេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245088-2022-06-06-11-07-02.html" (accessed date 25-June-2022 at 10 AM)

[៣៩] Fresh News, "សហព័ន្ធនិស្សិត បញ្ញាវ័ន្ត ប្រជាធិបតេយ្យកម្ពុជា ចេញសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245067-2022-06-06-09-27-45.html" (accessed date 25-June-2022 at 10 AM)

[៤០] Fresh News, "អង្គការមូលនិធិអភិវឌ្ឍន៍និស្សិតឥស្លាម៖ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងតម្លាភាព ក្នុងលំហសិទ្ធិសេរីភាពពេញលេញ", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245070-2022-06-06-09-33-35.html" (accessed date 25-June-2022 at 10 AM)

សហព័ន្ធសន្តិភាពពិភពលោក (UPF) ដែលជាជនជាតិកូរ៉េខាងត្បូង បាននិយាយថា តាមរយៈការបោះឆ្នោត គឺប្រជាធិបតេយ្យរបស់កូរ៉េខាងត្បូង និងកម្ពុជា មានលក្ខណៈស្រដៀងគ្នា។ លោក យុន យ៉ុង ហូ បានឱ្យដឹងបែបនេះ ក្នុងសន្និសីទនាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ដើម្បីបង្ហាញពី លទ្ធផលនៃការសង្កេតការណ៍របស់ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ដែលបានចូលរួមសង្កេត ការណ៍ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥។ អគ្គនាយក នៃអង្គការសហព័ន្ធសន្តិភាព ពិភពលោក បានបញ្ជាក់យ៉ាងដូច្នេះថា «តាមពិតទៅប្រជាធិបតេយ្យកម្ពុជា និងកូរ៉េ បើមើលទៅមាន សភាពស្រដៀងគ្នា។ អញ្ចឹងនេះជាអ្វី ដែលខ្ញុំបានឃើញជាក់ស្តែង នូវប្រជាធិបតេយ្យនៅកម្ពុជា ពេលខ្ញុំ ចូលរួមបំពេញភារកិច្ច។ ចំណុចស្រដៀងគ្នា គឺមាន ២ រួមមាន ទីមួយមានប្រើទឹកពណ៌ខ្មៅ ដែលលុបមិន ជ្រះពីដៃ ក្រោយប្រជាពលរដ្ឋបោះឆ្នោត គាត់ជ្រលក់ចង្អុលដៃ។ ខ្ញុំធ្លាប់មានបទពិសោធន៍ នៅអាហ្វ្រិក អាមេរិក និងអឺរ៉ុបជាដើម ក៏ប៉ុន្តែនេះជារបៀបមួយ នៃការរៀបចំរបស់ គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត ដើម្បីជាសញ្ញាណសម្គាល់ ដែលពលរដ្ឋ បានបោះឆ្នោត។ ចំណុចមួយទៀត ខ្ញុំឃើញមុនពេល បោះឆ្នោត អំឡុងពេលបោះឆ្នោត វាប្រៀបបីដូចជា ពិធីបុណ្យមួយ មានជំរុញពលរដ្ឋឱ្យមាន ភាពសប្បាយរីករាយក្នុងការបោះឆ្នោតជ្រើសរើស ថ្នាក់ដឹកនាំ របស់ពួកគេ»។[៤១]

អ្នកសង្កេតការណ៍ជនជាតិចិន៖ ការបោះឆ្នោតឃុំសង្កាត់ អាណត្តិទី៥ ឆ្លុះបញ្ចាំងពីឆន្ទៈពលរដ្ឋកម្ពុជា និងវឌ្ឍនភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប្រធានប្រតិភូក្រុមអ្នក សង្កេតការណ៍ជនជាតិចិន បានលើកឡើងថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ បានឆ្លុះបញ្ចាំងពីឆន្ទៈរបស់ពលរដ្ឋកម្ពុជា និងឆ្លុះបញ្ចាំង ពីវឌ្ឍនភាពលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេស កម្ពុជាផងដែរ។ ប្រធានប្រតិភូក្រុមអ្នកសង្កេតការណ៍ជនជាតិចិន បានបញ្ជាក់យ៉ាងដូច្នេះថា «ថ្ងៃម្សិលមិញ គឺខ្ញុំនិងសហការី បានទៅសង្កេតការណ៍បោះឆ្នោត នៅមណ្ឌលបោះឆ្នោតមួយចំនួន នៅក្រុងតាខ្មៅ ខេត្តកណ្តាល និងរាជធានីភ្នំពេញ។ យើងសង្កេតឃើញ មណ្ឌលបោះឆ្នោតទាំងនោះ មានភាព សណ្តាប់ធ្នាប់ល្អប្រសើរ ប្រជាជនទៅបោះឆ្នោត យ៉ាងរួសរាយ។ អ្វីដែលខ្ញុំនិយាយ គឺខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ដូច្នេះខ្ញុំយល់ថា ការបោះឆ្នោតឃុំសង្កាត់លើកនេះ គឺជាការបោះឆ្នោតមួយ ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។ ខ្ញុំគិតថា ការបោះឆ្នោតនេះបានធានាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសសិទ្ធិបោះឆ្នោត របស់ប្រជាជនកម្ពុជា បានឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាជនកម្ពុជា និងឆ្លុះបញ្ចាំង នូវវឌ្ឍនភាព លទ្ធិប្រជាធិបតេយ្យ នៅប្រទេសកម្ពុជា»។ លោកបន្តថា «ដូច្នេះយើងវាយតម្លៃខ្ពស់ និងកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងគ្រប់ប្រការ ដែលរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ហ៊ុន សែន

[៤១] Fresh News, "អ្នកសង្កេតការណ៍ជនជាតិកូរ៉េខាងត្បូង៖ ប្រជាធិបតេយ្យកូរ៉េខាងត្បូង និងកម្ពុជា មានលក្ខណៈស្រដៀងគ្នា", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245039-2022-06-06-05-11-54.html" ( accessed date 25-June-2022 at 10 AM)

ជានាយករដ្ឋមន្ត្រី បានធ្វើ ដើម្បីឱ្យការបោះឆ្នោតលើកនេះ បានរលូន និងកិច្ចខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត»។[៤២]

ជារួម អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ មកពី៧៥អង្គភាព ដែលមកពីបណ្តាប្រទេសមួយចំនួន ដូចជា ចិន ម៉ាឡេស៊ី និងហ្វីលីពីន ជាដើម បានចាត់ទុកការបោះឆ្នោត ឃុំ-សង្កាត់ អាណត្តិទី៥ នេះ ថាមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព ដែលជាការបញ្ជាក់ពីការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជានាពេលបច្ចុប្បន្ន។ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ដែលមកតាមការអញ្ជើញរបស់ គណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត ទាំងនោះបានកត់សម្គាល់ថា បរិយាកាសនៅថ្ងៃបោះឆ្នោត មានភាពស្ងប់ស្ងាត់ ដោយគ្មានបាតុភាពហិង្សា ឬការតវ៉ាណាមួយឡើយ។[៤៣] ក្នុងសន្និសីទសារព័ត៌មានដែល មានការចូលរួមពីតំណាងអង្គការនានា ជាង៧ម៉ឺននាក់ នៅសណ្ឋាគារ Hayat រាជធានីភ្នំពេញ កាលពី ថ្ងៃទី៦ ខែមិថុនា លោក Yun Young Ho អង្គការសម្ព័ន្ធសន្តិភាពសកល (UPF) និងជាប្រធាន វេទិកា បណ្តុំគំនិតសកលឆ្នាំ២០២២ បាននិយាយថាពេញមួយរយៈពេល នៃយុទ្ធនាការចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ដំណើរការសំខាន់ៗទាំងអស់ត្រូវ បានធ្វើឡើងដោយរលូន ស្ងប់ស្ងាត់ សន្តិភាព តម្លាភាព សេរី និងមានរបៀប។ មិនមានការបង្ហាញពី ការគំរាមកំហែង ឬភាពមិនប្រក្រតីនៃប្រភេទ ណាមួយអាចត្រូវ បានគេសង្កេតឃើញនោះទេ។ លោកថា ផ្អែកលើបទពិសោធន៍ផ្ទាល់នៅថ្ងៃបោះឆ្នោត គណៈប្រតិភូចង់ផ្តល់ ការវាយតម្លៃលើ ដំណើរការបោះឆ្នោត ដូចតទៅ៖

(ក) ពីការចុះសួរសុខទុក្ខតាមការិយាល័យបោះឆ្នោតមួយចំនួន មុនម៉ោងបើកការបោះឆ្នោត គណៈប្រតិភូអាចសង្កេតមើលដំណើរការរៀបចំបានល្អ ខណៈបុគ្គលិក គ.ជ.ប បានបំពេញភារកិច្ច ប្រកបដោយវិជ្ជាជីវៈ និងសុចរិតភាពខ្ពស់។

(ខ) តាមរយៈការសង្កេតដោយចៃដន្យនៃដំណើរការបោះឆ្នោត នៅតាមការិយាល័យបោះ ឆ្នោត នានាក្នុងរាជធានីភ្នំពេញ និងនៅតាមទីប្រជុំជន និងជាយក្រុងដែលនៅជាប់គ្នា គណៈប្រតិភូ បានកត់ សម្គាល់ថា អាជ្ញាធរពាក់ព័ន្ធទាំងអស់របស់កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការផ្តល់ នូវលក្ខខណ្ឌ អំណោយផលសម្រាប់គ្រប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោត។

---

[៤២] Fresh News, "អ្នកសង្កេតការណ៍ជនជាតិចិន៖ ការបោះឆ្នោតឃុំសង្កាត់ អាណត្តិទី៥ ឆ្លុះបញ្ចាំងពីឆន្ទៈពលរដ្ឋកម្ពុជា និងវឌ្ឍនភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា", "2022-06-06", "http://www.freshnewsasia.com/index.php/en/localnews/245043-2022-06-06-06-00-55.html" (accessed date 25-June-2022 at 10 AM)

[៤៣] Khmer Times, "អ្នកសង្កេតការណ៍ថាការបោះឆ្នោតមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព", "June 7, 2022", "Soth Koemsoeun", "https://www.khmertimeskh.com/501089774/អនកសងកេតការណេថក/?p=1089774" (accessed date 25-June-2022 at 10 AM)

លោកបន្តថា ជារួម គណៈប្រតិភូមានទស្សនៈថា ការបោះឆ្នោតត្រូវបានរៀបចំដោយជោគជ័យ ក្នុងបរិយាកាសសេរី យុត្តិធម៌ បរិយាប័ន្ន សន្តិភាព តម្លាភាព និងសុវត្ថិភាព។

លោក Ramin Mamandov សមាជិកសភាមកពីប្រទេស Azerbaijan បាននិយាយកាលពីនៅថ្ងៃបោះឆ្នោត គណៈប្រតិភូបានទៅមើលការិយាល័យបោះឆ្នោតភ្លាមៗមុនពេលពួកគេបើក ដូច្នេះគណៈប្រតិភូអាចមើលការត្រៀមរៀបចំរបស់បុគ្គលិក គ.ជ.ប ដើម្បីធានាថាដំណើរការបោះឆ្នោត មានភាពសំខាន់។ លោកបន្តថាជាលទ្ធផល គណៈប្រតិភូបានកត់សម្គាល់ថា វិជ្ជាជីវៈ និងភាពស្មោះត្រង់របស់បុគ្គលិក គ.ជ.ប មានស្តង់ដារខ្ពស់ និងហួសពីការសង្ស័យសមហេតុផល។ ប្រតិភូក៏បានអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួន នៅតាមការិយាល័យ បោះឆ្នោត មួយចំនួនផងដែរ ហើយគណៈប្រតិភូបានសង្កេតឃើញថា អាជ្ញាធរកម្ពុជាគ្រប់លំដាប់ថ្នាក់ បានបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់គ្រប់គណបក្សនយោបាយទាំងអស់ក្នុងការចូលរួមការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ទូទាំងប្រទេស។ អត្រាអ្នកទៅបោះឆ្នោតមានលើសពី ៧៧,៩១ ភាគរយនៃបញ្ជី ឈ្មោះអ្នកបោះឆ្នោត ដែលបង្ហាញពីការចូលរួមយ៉ាងសកម្មរបស់ប្រជាជនកម្ពុជាក្នុងដំណើរការនយោបាយ និងលទ្ធិប្រជាធិបតេយ្យ ជាពិសេសក្នុងការលើកកម្ពស់តម្លៃសិទ្ធិមនុស្ស និងគោលការណ៍លទ្ធិ ប្រជាធិបតេយ្យ។ លោកលើកឡើងថា៖ «យើងអរគុណចំពោះឱកាសក្នុងការសង្កេតមើលដោយផ្ទាល់ នូវដំណើរលទ្ធិប្រជា ធិបតេយ្យដែលកំពុងបន្តនៃប្រទេសកម្ពុជា និងរីករាយយ៉ាងក្រៃលែងក្នុងការអបអរសាទរដល់ គ.ជ.ប សម្រាប់វិជ្ជាជីវៈរបស់ខ្លួន និងប្រជាជនកម្ពុជាសម្រាប់ការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត»។

លោក Tompen Virakvitou ប្រធានអង្គការអភិវឌ្ឍន៍ពន្លឺសម្រាប់ជនងាយរងគ្រោះបំផុត និយាយថា លោកជូនពរកម្ពុជាជោគជ័យគ្រប់យ៉ាងក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ សន្តិភាព និងការអភិវឌ្ឍ។ លោកបន្តថា៖ «ភាពជោគជ័យនៃការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ នៅតែជាជំហានដ៏សំខាន់ មួយទៀតក្នុងការជំរុញកំណែទម្រង់ដែលកំពុងបន្តរបស់កម្ពុជា ដើម្បីសម្រេចបាននូវសេចក្តីប្រាថ្នារបស់ ប្រជាពលរដ្ឋចំពោះសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍»។ លោកបន្ថែមថា៖ «គណបក្សនយោបាយ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវសហការគ្នាក្នុងន័យ ស្ថាបនាជាមួយប្រជាពលរដ្ឋ ដើម្បីធានាបាននូវស្ថិរភាពសង្គម សន្តិភាព សុខដុមរមនា និងរួមចំណែក អភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែរីកចម្រើន ដែលនឹងជួយធានាបាននូវសន្តិភាព និងស្ថិរភាពក្នុងតំបន់ និងក្រៅប្រទេស»។

លោកស្រី កែវ សំបូរ អង្គការទ្រទ្រង់ស្ត្រីខ្មែរ (cows) និយាយថាដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសន្តិវិធី និងរលូនដោយសេរី ត្រឹមត្រូវ និងតម្លាភាព ដែលគណបក្សនយោបាយប្រកួតប្រជែងបានចូលរួមដោយសេរីក្នុងដំណើរការបោះឆ្នោតទាំងមូលដោយមិនមានការរំខាន។ លោកស្រីបន្តថា៖ «គ្រប់ភាគីទាំងអស់មានឱកាស និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដែលបង្ហាញ ពីដំណើរការប្រជាធិបតេយ្យសមរម្យនៅកម្ពុជា។ ប្រព័ន្ធតម្លាភាពមួយត្រូវបានរៀបចំដើម្បីធានាឱ្យអ្នកសង្កេតការណ៍មកពីគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីឃ្លាំមើលដំណើរការបោះឆ្នោត

ទាំងមូល»។ លោកស្រីបន្ថែមថា៖ «ការរាប់សន្លឹកឆ្នោតត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពដោយប្រើយន្តការដ៏មានប្រសិទ្ធភាពដោយមានការចូលរួមពីអ្នកសង្កេតការណ៍»។

កំប៉ុន្តែសម្រាប់ក្រុមអង្គការសង្គមស៊ីវិលនៅក្នុងប្រទេស បានកត់សម្គាល់ ពីបញ្ហាបំភិតបំភ័យ សិទ្ធិរបស់ពលរដ្ឋ ដែលកើតមាន នៅតាមការិយាល័យនាអំឡុងពេលបោះឆ្នោត និងបានចាត់ទុកថាការបោះឆ្នោតពេលនេះ មិនមានប្រជាធិបតេយ្យ ដ្បិតមានការគាបសង្កត់លើសិទ្ធិសេរីភាពពលរដ្ឋ។

អង្គការសិទ្ធិមនុស្សលីកាដូ ដែលឃ្លាំមើលសិទ្ធិរបស់ពលរដ្ឋក្នុងថ្ងៃបោះឆ្នោតនេះឱ្យដឹងថា អង្គការលីកាដូបានទទួលការរាយការណ៍ពីរាជធានី-ខេត្តចំនួន១៦ផ្សេងៗគ្នា អំពីវត្តមានរបស់អាជ្ញាធរមូលដ្ឋានអង្គុយចាំនៅក្នុង ឬក្រៅទីតាំងបោះឆ្នោត ឬជួយសម្របសម្រួលឱ្យពលរដ្ឋបានចូលទៅកាន់ការិយាល័យបោះឆ្នោត។ អង្គការលីកាដូ ឱ្យដឹងទៀតថា អ្នកទាំងនោះគឺជាមេភូមិមេឃុំឬចៅសង្កាត់ ឬចៅហ្វាយស្រុកក៏ដូចជាអាជ្ញាធរផ្សេងទៀត។ ប្រភពដដែលបន្តថាភាគច្រើននៃករណីទាំងនេះ អាជ្ញាធរ បានកត់ត្រាឈ្មោះឬចំនួនប្រជាពលរដ្ឋដែលបានទៅបោះឆ្នោត។ អង្គការលីកាដូឱ្យដឹងទៀតថា មេភូមិ និងអនុប្រធានភូមិត្រូវបានមើលឃើញថា អង្គុយនៅក្រៅច្រកចូលនៃទីតាំងបោះឆ្នោត និងតម្រូវឱ្យពលរដ្ឋប្រាប់ឈ្មោះពួកគាត់ក្រោយពីការបោះឆ្នោត។ ក្រៅពីនេះ ក៏មានការរាយការណ៍អំពី ករណីដែលអាជ្ញាធរមូលដ្ឋានចុះតាមផ្ទះប្រជាពលរដ្ឋនីមួយៗដើម្បីសួរនាំប្រជាពលរដ្ឋអំពីអ្នកដែលពួកគេបោះឆ្នោតឱ្យ និងការបង្ហាញវត្តមាននៃទាហានប្រដាប់ដោយអាវុធនៅក្បែរទីតាំងបោះឆ្នោត។

បណ្តាញអាស៊ីដើម្បីការបោះឆ្នោតដោយសេរី (ANFREL) បានចេញរបាយការណ៍វាយតម្លៃជាមុនថា ការបោះឆ្នោតឃុំ-សង្កាត់ នឹងមិនមានលទ្ធផលបោះឆ្នោតពិតប្រាកដ និងត្រឹមត្រូវតាមច្បាប់នោះទេ ប្រសិនបើការគំរាមកំហែងប្រឆាំងនឹងគណបក្សជំទាស់ និងសង្គមស៊ីវិល នៅតែកើតមាន។ បើតាមអង្គការអន្តរជាតិមួយនេះ ប្រទេសកម្ពុជានៅតែខ្វះស្តង់ដារបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ។

ប្រធានអង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា ច្រាក់ (CHRAC) លោក រស់ សុដ្ឋា ដែលបានទៅឃ្លាំមើលមណ្ឌលបោះឆ្នោតចំនួនពីរមណ្ឌលនៅភ្នំពេញ លោកសង្កេតឃើញទិដ្ឋាទូទៅដំណើរការធម្មតា។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ (Geneva) ប្រទេសស្វីស (Switzerland) អំពាវនាវដល់រដ្ឋាភិបាល ឱ្យធានាថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព និងសុវត្ថិភាព ដែលលើកស្ទួយដល់ភាពចម្រុះផ្នែកនយោបាយ និងការគោរពសេរីភាពជាមូលដ្ឋាន»។[៤៤] ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការ

[៤៤] RFA, "អង្គការសង្គមស៊ីវិលរកឃើញថា មានការគំរាមកំហែងពលរដ្ឋម្ចាស់ឆ្នោតក្នុងថ្ងៃបោះឆ្នោត", "សុ ជីវី", "2022.06.06", "https://www.rfa.org/khmer/news/politics/opinions-of-civil-society-groups-on-5th-mandate-commune-election-06062022011633.html" (accessed date 25-June-2022 at 10 AM)

សហប្រជាជាតិសម្តែងការព្រួយបារម្ភ ដោយសារតែឃើញមានលំនាំនៃការគំរាមកំហែង ការបំភិតបំភ័យ និងការចាប់ខ្លួនបេក្ខជនមួយចំនួនដាក់ពន្ធនាគារ។

ចំណែកអង្គការសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) ក៏បានថ្កោលទោសចំពោះយុទ្ធនាការយាយី និងបំភិតបំភ័យលើសមាជិកគណបក្សប្រឆាំងអំឡុងពេលឃោសនាបោះឆ្នោត ជាពិសេសការធ្វើទុក្ខបុកម្នេញលើបេក្ខជនគណបក្សភ្លើងទៀន។ សមាជិកសភាម៉ាឡេស៊ី និងជាសមាជិកនៃអង្គការ APHR អ្នកស្រី ម៉ារៀ ជិន អាប់ឌុលឡា (Maria Chin Abdullah) លើកឡើងថា វាជារឿងដែលមិនអាចទៅរួចនោះទេ ក្នុងការរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ក្នុងបរិយាកាសមួយដែលពោរពេញទៅដោយការធ្វើទុក្ខបុកម្នេញលើអ្នកនយោបាយប្រឆាំង។ អ្នកស្រីបន្តថា ថ្វីបើគណបក្សចំនួន១៧ ត្រូវបានគេអនុញ្ញាតឱ្យឈរឈ្មោះបោះឆ្នោតក្តី ដំណើរការទាំងមូលមិនអាចចាត់ទុកថា ជាការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងពហុបក្សបានឡើយ នៅពេលដែលគណបក្សប្រជាជនកម្ពុជា មិនព្រមឱ្យអ្នកដែលចូលរួមប្រកួតប្រជែង ធ្វើយុទ្ធនាការឃោសនាបានដោយសេរី និងមានសុវត្ថិភាពនោះ។

ដោយឡែក អតីតរដ្ឋមន្ត្រីការបរទេសថៃ និងជាសមាជិកអង្គការ APHR លោក កាសិត ភីរម្យ (Kasit Piromya) លោកសរសេរនៅក្នុងអត្ថបទមួយចុះផ្សាយជាភាសាអង់គ្លេសនៅលើគេហទំព័រអនឡាញ ឈ្មោះ ឌឹ ឌីប្លូម៉ាត (The Diplomat) កាលពីថ្ងៃទី០១ ខែមិថុនា ថា ពិភពលោកមិនត្រូវភាន់ច្រឡំដោយសារតែភាពពហុបក្សដែលមានតែសម្បកក្រៅនៅកម្ពុជានោះទេ។ លោកផ្តល់អនុសាសន៍ថា ប្រទេសក្នុងតំបន់ និងដៃគូដទៃទៀតចាំបាច់ត្រូវបញ្ជូនសារឱ្យច្បាស់ទៅកម្ពុជាថា ការបោះឆ្នោតមិនត្រឹមត្រូវបែបនេះនឹងមិនត្រូវបានគេទទួលស្គាល់នូវភាពស្របច្បាប់ដល់គណបក្សកាន់អំណាចនោះទេ ជាពិសេសក្នុងពេលដែលសេរីភាពជាមូលដ្ឋាន និងសិទ្ធិមនុស្សត្រូវបានគណបក្សនេះយកមកជាន់ឈ្លីស្ទើរតែជារៀងរាល់ថ្ងៃនោះ។[៤៥]

លោក កន សាវាង្ស មន្ត្រីជាន់ខ្ពស់ផ្នែកអង្កេត និងតស៊ូមតិនៃអង្គការខុមហ្វ្រែល (Comfrel) មើលឃើញថាមេភូមិ មេឃុំមួយចំនួនបានធ្វើសកម្មភាពដោយសេរីនៅក្នុងបរិវេណការិយាល័យបោះឆ្នោត ដែលផ្ទុយទៅនឹងច្បាប់បោះឆ្នោត។ លោកបន្តថា បញ្ហានេះ ពុំឃើញគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតចុះត្រួតពិនិត្យ ឬមានចំណាត់ការណាមួយណានោះទេ៖ «នីតិវិធីមានតែប៉ឹងទេ ប៉ុន្តែប៉ឹងហើយគេមិនដោះស្រាយ វាជារឿងមួយយើងមានអំណះអំណាងគ្រប់គ្រាន់ថា គ.ជ.ប ឬគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ឬក៏គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោតហ្នឹងអត់យកចិត្តទុកដាក់។ លោកបន្ថែមថា

[៤៥] RFA, "លទ្ធផលបឋម៖ បក្សភ្លើងទៀនមានប្រៀបជាងបក្សកាន់អំណាចតែ ៤ឃុំប៉ុណ្ណោះនៅទូទាំងប្រទេស ខណៈការបោះឆ្នោតរងការរិះគន់ថា អាក្រក់ជាងពេលណាៗទាំងអស់", "មាន រិទ្ធិ", "2022.06.05", "https://www.rfa.org/khmer/news/politics/early-results-out-of-1652-communes-candlelight-party-won-just-4-communes-and-ruling-party-cpp-won-the-rest-06052022220830.html" (accessed date 25-June-2022 at 10 AM)

យន្តការ ដែលដោះស្រាយធ្វើតាមរយៈបណ្ដឹង ឬត្រូវតែប្ដឹងបើសិនមើលឃើញភាពមិនប្រក្រតីណាមួយកើតឡើង ដែលយល់ឃើញថា មិនត្រឹមត្រូវ»។[៤៦]

ចំណែក លោក សម រង្ស៊ី អតីតមេបក្សប្រឆាំងដែលកំពុងនិរទេសខ្លួនបាននិយាយនៅលើទំព័រ Facebook របស់លោកកាលថាកាលពីថ្ងៃទី៦ ខែមិថុនា ថា៖ «ការបោះឆ្នោតទាំងនេះអាក្រក់ជាងការបោះឆ្នោតលើកមុនៗ ទាំង តម្លាភាព និងភាពស្មោះត្រង់ ដោយសារតែពេលនេះ សាធារណជនមិនត្រូវបានអនុញ្ញាត ឱ្យធ្វើជា សាក្សីនៃការរាប់សន្លឹកឆ្នោតដូចការទាមទារដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)»។ លោកបន្តថា៖ «គ.ជ.បកំពុងតែបំពានច្បាប់របស់ខ្លួនដែលអនុញ្ញាតឱ្យគណបក្សកាន់អំណាច របស់លោក ហ៊ុន សែន បោកតាមការចង់បាន»។ លោកបានជំរុញឱ្យសហគមន៍អន្តរជាតិជួយប្រជាជនកម្ពុជាឱ្យមានសិទ្ធិ គ្រប់គ្រងជោគវាសនារបស់ខ្លួនក្នុងការបោះឆ្នោតជាតិខាងមុខ។[៤៧]

ជារួម យើងសង្កេតឃើញថា អ្នកសង្កេតការណ៍ជាតិ សរុបចំនួន ៧៤,៨៨៥រូប មកពី៧២ស្ថាប័ន្ត មកពីសហគមនិងអង្គការអ្នក សង្កេតការណ៍អន្តរជាតិ ចំនួន១១០រូប មកពី១៩ស្ថាប័ន ព្រមទាំងមានភ្ញៀវពិសេសចំនួន២៣រូប មកពី៥ស្ថាប័នផងដែរ ក្នុងនោះមានស្ថានទូតជប៉ុន អូស្ត្រាលី និងរុស្ស៊ីជាដើម បានវាយតម្លៃខ្ពស់ចំពោះការរៀបចំរបស់ គ.ជ.ប ថាមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព ដែលជាការបញ្ជាក់ពីការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជានាពេលបច្ចុប្បន្ន។ ក៏ប៉ុន្តែសម្រាប់ក្រុមអង្គការសង្គមស៊ីវិលនៅក្នុងប្រទេស បានកត់សម្គាល់ ពីបញ្ហាបំភិតបំភ័យសិទ្ធិ របស់ពលរដ្ឋ ដែលកើតមាននៅតាមការិយាល័យនាអំឡុងពេលបោះឆ្នោត និងបានចាត់ទុកថា ការបោះឆ្នោតពេលនេះ មិនមានប្រជាធិបតេយ្យ ដ្បិតមានការគាបសង្កត់លើសិទ្ធិសេរីភាពពលរដ្ឋ។

---

[៤៦] RFA, "មន្ត្រីបក្សភ្លើងទៀន៖ អាជ្ញាធរបង្កភាពភ័យខ្លាចដល់ពលរដ្ឋនៅមណ្ឌលបោះឆ្នោតមួយចំនួន", "យន់ សាមៀន", "2022.06.05", "https://www.rfa.org/khmer/news/politics/authorities-intimidate-people-in-some-polling-stations-06052022135756.html" (accessed date 25-June-2022 at 10 AM)

[៤៧] Khmer Times, "អ្នកសង្កេតការណ៍ថាការបោះឆ្នោតមានភាពយុត្តិធម៌ ដោយសន្តិវិធី និងតម្លាភាព", "Soth Koemsoeun", "June 7, 2022", "https://www.khmertimeskh.com/501089774/អនកសងកេតការណេថក/?p=1089774" (accessed date 25-June-2022 at 10 AM)

# ៥. គោលនយោបាយរបស់បក្សធំៗ២

## ៥.១. គោលនយោបាយគណបក្សប្រជាជន

ទិសដៅធំៗនៃ គោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ ២០២២-២០២៧ របស់ គណបក្សប្រជាជនកម្ពុជា ដើម្បីធានាបន្តការអភិវឌ្ឍឃុំ សង្កាត់ ឱ្យបានសម្រេច ជោគជ័យតាមទិសដៅដូចខាងក្រោម ៖

១-ជាឃុំ សង្កាត់ដែលជានាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពរបស់ ប្រជាជនតាមគន្លងនីតិរដ្ឋ ដើម្បី លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងធ្វើឱ្យប្រជាជនបានរស់នៅដោយ សុខដុមរមនា ក្រោមម្លប់នៃសន្តិភាព

២-ជាឃុំ សង្កាត់ដែលមានសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមកាន់តែល្អប្រសើរ

៣-ជាឃុំ សង្កាត់ដែលជានាការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព តម្លាភាព និងជឿទុកចិត្ត -ប្រជាពលរដ្ឋទទួលបានសេវារដ្ឋបាលប្រកបដោយភាពងាយស្រួល សាមញ្ញ និងឆាប់រហ័ស តាមរយៈការរៀបចំយន្ត ការច្រកចេញចូលតែមួយ។ ការចុះបញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព ការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ

- កុមារ និងយុវជនបានរៀនសូត្រគ្រប់គ្នាប្រកបដោយសមធម៌ និងគុណភាព ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋ ការបង្កឱកាសគ្រប់យ៉ាងឱ្យកុមារ និងយុវជនបានចូលរៀន និងការបង្កើតសាលារៀនឱ្យទៅជិតលំនៅឋានប្រជាជន -ប្រជាជនទូទៅទទួលបានសេវាសុខភាពកាន់តែប្រសើរឡើង នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ហើយចូលរួម យ៉ាងសកម្មក្នុងការលើកកម្ពស់របៀប រស់នៅ តាមគន្លងថ្មី។ ប្រជាជនក្រីក្រ និងអ្នកខ្វះលទ្ធភាពទទួលបានសេវា ពិនិត្យ និងព្យាបាលជំងឺ ដោយឥតបង់ថ្លៃនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ
- គ្រប់ឃុំ សង្កាត់មានផ្លូវគមនាគមន៍កាន់តែច្រើន និងកាន់តែល្អ, មានអគ្គិសនី និងទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់, មានប្រព័ន្ធទឹកស្រោចស្រពដំណាំកាន់តែប្រសើរឡើង, មានសេវាទូរគមនាគមន៍ប្រកបដោយគុណភាព, មាន បរិស្ថានបៃតង អនាម័យស្អាត, មានការការពារ ការអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព -បន្តមិនយកពន្ធដីកសិកម្មរបស់កសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ បែងចែកដី និងផ្តល់កម្មសិទ្ធិដីជូនគ្រួសារ
- ក្រីក្រគ្មានដីសម្រាប់ស្នាក់នៅ និងបង្កបង្កើនផលចិញ្ចឹមជីវិត ដែលបានអនុវត្តស្របតាមលក្ខខណ្ឌសម្បទានដីសង្គមកិច្ច

៤- ជាឃុំ សង្កាត់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីលើកស្ទួយជីវភាពប្រជាជន តាមរយៈការបង្កើនការងារ, ការពង្រីក មុខរបរ ការអភិវឌ្ឍវិស័យកសិកម្ម និងផលិតកម្មផ្សេងៗទៀត,

ការពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម និង សិប្បកម្ម, ការផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ទាប សមរម្យសម្រាប់បង្កើត និងពង្រីកមុខរបរ, ការរក្សាស្ថិរភាពថ្លៃ ស្បៀងអាហារ និងថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ, ការធ្វើអន្តរាគមន៍ពីរដ្ឋលើថ្លៃលក់កសិផលរបស់ប្រជា ពលរដ្ឋដោយរក្សាបានសេដ្ឋកិច្ចទីផ្សារ និងសន្តិសុខសង្គម។ អាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋ មានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើតូប រាន ស្តង់លក់ដូរ នឹងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះជូនកូនចៅ ឬអ្នកដទៃ

៥ - ជាឃុំ សង្កាត់ដែលលើកកម្ពស់ការគាំពារសង្គម និងលើកកម្ពស់ស្ថានភាពរស់នៅរបស់ស្រ្តី យុវជន កុមារ ជនមាន ពិការភាព ជនចាស់ជរា ជនជាតិដើមភាគតិច អតីតយុទ្ធជន គ្រួសារក្រីក្រ និងប្រជាជនងាយរងគ្រោះផ្សេងទៀត

៦ - ជាឃុំ សង្កាត់ ដែលលើកកម្ពស់គណនេយ្យ ភាពចំពោះប្រជាពលរដ្ឋ យុត្តិធម៌សង្គម និងភាពស្អាតស្អំ គ្មានការ រំលោភអំណាច និងគ្មានអំពើពុករលួយ

៧-ជាឃុំ សង្កាត់ដែលមានស្វ័យភាព សិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីធានា ការអភិវឌ្ឍមូលដ្ឋាន និងការការពារផលប្រយោជន៍របស់ប្រជាជន។

## ៥.២. គោលនយោបាយគណបក្សភ្លើងទៀន

នៅថ្ងៃបិទបញ្ចប់ការចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលមានរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែមីនានេះ គណបក្សភ្លើងទៀន បានដាក់បេក្ខជនជាង ១.៦០០ ឃុំសង្កាត់នៅ ២៥ខេត្តក្រុង ក្នុងចំណោមឃុំសង្កាត់ ១.៦៥២ ដែលចំនួននេះគឺនៅក្រោមតែគណបក្សប្រជាជនកម្ពុជាមួយប៉ុណ្ណោះ។[៤៨]

ក្រោយពីលោក ថាច់ សេដ្ឋា អនុប្រធានទី១ និងជាអ្នកនាំពាក្យគណបក្សភ្លើងទៀន បានប្រកាសកាលពីខែមីនាកន្លងទៅ ថា បើបរិយាកាសមិនអំណោយផល ពោលគឺសមាជិករបស់ខ្លួននៅ តែត្រូវបានចាប់ខ្លួន ហើយគ.ជ.បបន្តបដិសេធពាក្យសុំបេក្ខជនរបស់ នោះគឺមិនអាចចូលរួមក្នុង ការបោះឆ្នោតឃុំសង្កាត់បានទេ។[៤៩] នៅថ្ងៃអាទិត្យទី១៥ ខែឧសភា ឆ្នាំ២០២២ គណបក្សភ្លើងទាន បានធ្វើសមាជគណបក្ស

[៤៨] RFA, "គណបក្សភ្លើងទៀន ដាក់បេក្ខជនបានជាង ១.៦០០ ឃុំសង្កាត់នៅ២៥ខេត្តក្រុង", "សុជីវី", "2022.03.06", "https://www.rfa.org/khmer/news/politics/only-4-political-parties-have-arranged-candidates-for-commune-elections-across-the-country-03062022091812.html" ( accessed date 25-June-2022 at 10 AM)

[៤៩] AMS, "អ្នកនាំពាក្យ គ.ជ.ប ៖ ការប្រកាសធ្វើពហិការបស់គណបក្សភ្លើងទៀន គឺមិនប៉ះពាល់ដល់ដំណើរការនៃបោះឆ្នោតនោះទេ", "ពលជ័យ", "30 មិនា 2022", "https://ams.com.kh/central/detail/759962" ( accessed date 25-June-2022 at 10 AM)

លើកទី២ដោយសម្រេចជាផ្លូវការចូលរួមការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ នៅថ្ងៃទី៥ មិថុនា។[៥០] ក្នុងនោះគណបក្សបានដាក់ចេញគោលនយោបាយ៧ចំណុច។

**<u>ចំណុចទី១</u>៖** ស្តីពីសិទ្ធិអំណាច៖ ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមផ្តល់ មតិយោបល់ដល់ក្រុមប្រឹក្សាឃុំសង្កាត់ គឺជាគោលនយោបាយដែលរដ្ឋាភិបាលដឹកនាំ ដោយគណបក្សប្រជាជនកម្ពុជាបានអនុវត្តជាច្រើនអាណត្តិមកហើយ។ ប្រជាពលរដ្ឋមានសិទ្ធិចូលរួម ឬត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ឬចូលរួមក្នុងវេទិកាសាធារណៈ ដែលរៀបចំដោយមន្ត្រីថ្នាក់ជាតិ និងថ្នាក់ឃុំសង្កាត់ដើម្បីស្តាប់ការ សម្រេចរបស់អាជ្ញាធរ មូលដ្ឋានផង និងផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សាផង។

**<u>ចំណុចទី២</u>៖** ស្តីពីសេវា សាធារណៈ ក៏រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា បានធ្វើកំណែទម្រង់ដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យ បានឆាប់រហ័ស និងមិនយកកម្រៃហើយបើត្រូវបង់សេវាក៏ត្រូវបង់ទៅតាមការកំណត់របស់រដ្ឋ។ ការបង្កើតការិយាល័យ ច្រកចេញចូលតែមួយគឺជាឧទាហរណ៍ជាក់ស្តែងដែលរដ្ឋាភិបាល គណបក្សប្រជាជនកម្ពុជា បានដាក់ឱ្យអនុវត្តជាច្រើនឆ្នាំមកហើយ និងកំពុងទទួលបានលទ្ធផលដ៏គាប់ប្រសើរ។ ប្រជាពលរដ្ឋកំពុងទទួលផលពីការិយាល័យច្រកចេញចូលតែមួយ តាមរយៈការទទួលបានសេវាឆាប់រហ័ស ងាយស្រួល និង ដោយគ្មានបង់កម្រៃសេវាក្រោមតុឡើយ។

**<u>ចំណុចទី៣</u>៖** ស្តីពីសន្តិសុខសុវត្ថិភាព៖ គ្មានគ្រឿងញៀន គ្មានអំពើអបាយមុខ ក៏គណបក្សភ្លើងទៀនចម្លងចេញពីគោលនយោបាយភូមិឃុំ មានរបស់គណបក្សប្រជាជនកម្ពុជាដែរ។ គោលនយោបាយភូមិឃុំ មានសុវត្ថិភាព ដែលត្រូវបានប្រកាសដាក់ចេញជាច្រើនឆ្នាំមកហើយ គឺសំដៅធ្វើឱ្យភូមិឃុំមានសន្តិសុខ ល្អ គ្មានគ្រឿងញៀន និងអំពើអបាយមុខនានា។ ទោះយ៉ាងណា បញ្ហាគ្រឿងញៀនគឺជាបញ្ហាប្រឈមរបស់ពិភពលោកទាំងមូលដែលគ្មានប្រទេសណា អាចលុបបំបាត់ ទាំងស្រុងបានឡើយរាប់ទាំងមហាប្រទេសជឿនលឿនផងដែរ។

**<u>ចំណុចទី៤</u>៖** ការការពារកម្មសិទ្ធិដីធ្លី និងធ្វើឱ្យពលរដ្ឋមានជីវភាពល្អប្រសើរ គឺជាអាទិភាពចម្បងរបស់រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា។ ក្រោយចាកចេញពីរបបខ្មែរក្រហម ពលរដ្ឋខ្មែរគ្មានកម្មសិទ្ធិឯកជនទេ រាប់ទាំងកម្មសិទ្ធិដីធ្លីផង។ ប៉ុន្តែគឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នេះហើយដែលបានដឹកនាំធ្វើកំណែទម្រង់រៀបចំឱ្យមានកម្មសិទ្ធិឯកជន និងកម្មសិទ្ធិដីធ្លីរហូតដល់បច្ចុប្បន្ន។ ហើយបើនិយាយពីការធ្វើឱ្យពលរដ្ឋមានជីវភាពធូរធា គ្មាននរណាអាចធ្វើបានដូចគណបក្សប្រជាជនកម្ពុជានោះទេ។ ចាប់តាំងពីបាតដៃទទេ គ្មានស្បែកជើងពាក់ គ្មានកង់ជិះ រហូតពលរដ្ឋខ្មែរ បាននិងកំពុងរស់ក្នុងភាពសម្បូរសប្បាយ យានយន្តស្ទះណែន ពេញផ្លូវដូចសព្វថ្ងៃ គឺជាស្នាដៃរបស់គណបក្សប្រជាជនកម្ពុជា។

**<u>ចំណុចទី៥</u>៖** ស្តីពីការខ្ចីបុល និងការបង្កើតមូលនិធិជួយជនក្រីក្រ ក៏ជាកិច្ចការដែលរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា បានធ្វើរួចហើយដែរ។ ជាក់ស្តែង ពលរដ្ឋខ្មែរជាច្រើនបានទទួល ផលពីសេវា

---

[៥០] RFI, "គណបក្សភ្លើងទៀនសម្រេចជាផ្លូវការចូលរួមបោះឆ្នោតឃុំសង្កាត់", "15/05/2022", "https://rfi.my/8PwY" ( accessed date 25-June-2022 at 10 AM)

កម្ចីឥណទានដើម្បីយក ទៅបង្កើតមុខរបរ អាជីវកម្ម និងទិញផ្ទះសម្បែងជាដើម។ ក្នុងករណីដែលពលរដ្ឋដែលជាកូន បំណុលជួបហានិភ័យ រដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ជួយដោះស្រាយ តាមរយៈការសម្របសម្រួលជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុដើម្បីពន្យារពេលនៃការសង ឬការរៀបចំឡើងវិញនូវឥណទានដូចករណីវិបត្តិកូវីដ១៩ ជាដើម។ និយាយពីមូលនិធិសម្រាប់ជួយគ្នាវិញ គឺមានស្ទើរតែគ្រប់ស្ថាប័ន។ ចំណែកពលរដ្ឋក្រីក្រក៏តែងតែ ទទួលបាននូវការយកចិត្តទុកដាក់ជួយពីសំណាក់អាជ្ញាធរផង កាកបាទក្រហមកម្ពុជាផង និងពីក្រុមការងារ ចុះជួយមូលដ្ឋានផង ក្រុមគ្រូពេទ្យស្ម័គ្រចិត្តផង។ល។

**<u>ចំណុចទី៦</u>៖** ស្តីពីប័ណ្ណព្យាបាលជំងឺដោយឥតគិតថ្លៃ៖ រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាបានអនុវត្តជាយូរមកហើយ តាមរយៈការផ្តល់ប័ណ្ណសមធម៌ជូនដល់ពលរដ្ឋក្រីក្រ និងការចេញកាត «បសស» ដល់បុគ្គលិក និយោជិតក្នុងវិស័យឯកជន និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀនដើម្បីទទួលបានការព្យាបាលជំងឺដោយឥតបង់ប្រាក់។ ក្រៅពីនោះ ក៏នៅមាន ក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះជួយព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ដល់មូលដ្ឋានទៀតផង។

**<u>ចំណុចទី៧</u>៖** ស្តីពីឱកាសដូចគ្នាក្នុងការអប់រំ ក៏រដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាបានដាក់ចេញជាយូរមកហើយដែរក្រោមទិសស្លោក «ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ»។ កំណែទម្រង់វិស័យអប់រំក៏កំពុងទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត និងទទួលបានការសាទរពីសំណាក់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន។

# ៦. លទ្ធផលនៃការបោះឆ្នោត និងបញ្ហាពាក់ព័ន្ធ

## ៦.១. លទ្ធផលបោះឆ្នោតផ្លូវការ

ក្រោយការបិទបញ្ចប់ទទួលពាក្យបណ្តឹងតវ៉ា នៅរសៀលថ្ងៃទី១៧ ខែមិថុនា និងបានដោះស្រាយចប់សព្វគ្រប់ ដូច្នេះ គ.ជ.ប. បានប្រកាសលទ្ធផលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នេះជាផ្លូវការបានហើយនៅថ្ងៃទី២៦ ខែនិថុនា ឆ្នាំ២០២២។

យោងតាមលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ ២០២២ ដែលចេញផ្សាយថ្ងៃអាទិត្យទី២៦ ខែមិថុនា ឆ្នាំ២០២២ ដោយ គ.ជ.ប បានឱ្យដឹងថា៖ អាណត្តិទី៥នេះ មានប្រជាពលរដ្ឋចេញទៅបោះឆ្នោត សរុបចំនួន ៧,៣៩៤,៤២៧ នាក់ ស្មើនឹង ៨០,៣២% សន្លឹកឆ្នោតបានការ សរុបចំនួន ៧.២៣៧.០៣៧ សន្លឹក និងសន្លឹកឆ្នោតមិនបានការ សរុបចំនួន ១៥៧.៣៩០ សន្លឹក។ [៥១]

[៥១] The National Election Committee, "លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (តារាងសំឡេងឆ្នោត និងភាគរយតាមគណបក្ស)",

"https://www.nec.gov.kh/khmer/content/5872"( accessed date 25-June-2022 at 12 AM)

ក្នុងចំណោមគណបក្សទាំង១៧ ដែលបានចូលរួមប្រកួតប្រជែង មានគណបក្សនយោបាយ តែ៩ ប៉ុណ្ណោះដែលបានទទួលអាសនៈក្រុមប្រឹក្សា សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលក្នុងនោះមាន៖

ទី១-គណបក្សប្រជាជនកម្ពុជា ទទួលបានសម្លេងសរុបចំនួន ៥,៣៧៨,៧៧៣ សម្លេង ស្មើនឹង ៧៤.៣២ភាគរយ និងទទួលបានអាសនៈចំនួន ៩,៣៧៦ អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន ១៦៤៨ឃុំ , ជំទប់ទី១ ចំនួន ១៦១៨ និងជំទប់ទី២ ចំនួន ២៦១ ។

ទី២-គណបក្សភ្លើងទៀន ទទួលបានសម្លេងសរុបចំនួន ១,៦១០,៥៥៦ សម្លេង ស្មើនឹង ២២.២៥ភាគរយនិងទទួលបានអាសនៈចំនួន ២,១៩៨ អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន ៤ឃុំ, ជំទប់ទី១ ចំនួន ២៥ និងជំទប់ទី២ ចំនួន ១៣៦០។

ទី៣-គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបានសម្លេងសរុបចំនួន ៩១,៧៩៨ សម្លេង ស្មើនឹង ១.២៧ ភាគរយ និងទទួលបានអាសនៈចំនួន ១៩ អាសនៈ, ជំទប់ទី១ ចំនួន ៤ និងជំទប់ទី២ ចំនួន១២។

ទី៤-គណបក្សខ្មែររួបរួមជាតិ ទទួលបានសម្លេងសរុបចំនួន ៦៣,៨៦៨ សម្លេង ស្មើ ០.៨៨ ភាគរយ និងទទួលបានអាសនៈចំនួន ១៣ អាសនៈ, ជំទប់ទី១ ចំនួន ១ និងជំទប់ទី២ ចំនួន ១០។

ទី៥-គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ទទួលបានសម្លេងសរុបចំនួន ៦,៨០៧ សម្លេង ស្មើ ០.០៩% និងទទួលបានអាសនៈចំនួន ៦ អាសនៈ, ជំទប់ទី១ ចំនួន ២ និងជំទប់ទី២ ចំនួន ២។

ទី៦-គណបក្សខ្មែរស្រឡាញ់ជាតិ ទទួលបានសម្លេងសរុបចំនួន ៣៣,២៥៩ សម្លេង ស្មើ ០.៤៦ភាគរយ និងទទួលបានអាសនៈចំនួន ៥ អាសនៈ, ជំទប់ទី១ ចំនួន ២ និងជំទប់ទី២ ចំនួន ២។

ទី៧-គណបក្សយុវជនកម្ពុជា ទទួលបានសម្លេងសរុបចំនួន ១៣,៨៤១ សម្លេង ស្មើ ០.១៩ ភាគរយ និងទទួលបានអាសនៈចំនួន ៣ អាសនៈ, ជំទប់ទី២ ចំនួន ៣។

ទី៨-គណបក្សកម្ពុជានិយម ទទួលបានសម្លេងសរុបចំនួន ៤,៨៥៦ សម្លេង ស្មើ ០.០៧ភាគរយ និងទទួលបានអាសនៈចំនួន ១ អាសនៈ, ជំទប់ទី២ ចំនួន ១។

ទី៩-គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ទទួលបានសម្លេងសរុបចំនួន ២,៤៦០ សម្លេង ស្មើ ០.០៣ភាគរយនិងទទួលបានអាសនៈចំនួន ១ អាសនៈ, ជំទប់ទី២ ចំនួន ១។[៥២]

## ៦.២. ស្ថានភាពក្រោយប្រកាសលទ្ធផលផ្លូវការ

[៥២] The National Election Committee, "លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (តារាងគណបក្សនយោបាយទទួលបានអាសនៈ)",

"https://www.nec.gov.kh/khmer/content/5870" ( accessed date 25-June-2022 at 12 AM)

## គណបក្សប្រជាជនកម្ពុជា ប្រកាសទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

គណបក្សប្រជាជនកម្ពុជា នៅល្ងាចថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២នេះ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយប្រកាសទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥។

តាមរយៈសេចក្តីថ្លែងការណ៍ គណបក្សប្រជាជនកម្ពុជា បានចាត់ទុកថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ បានប្រព្រឹត្តទៅស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាស អព្យាក្រឹត សន្តិសុខ របៀបរៀបរយ គ្មានអំពើហិង្សា និងការគំរាមកំហែង។

គណបក្សនេះបានកត់សម្គាល់ថា គ្រប់គណបក្ស ដែលបានចូលរួមបោះឆ្នោតមានឱកាសពេញលេញក្នុងការធ្វើសកម្មភាពស្របតាមបទបញ្ញត្តិនៃច្បាប់ ដើម្បីស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋខ្មែរជាង៨០% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានអនុវត្តយ៉ាងពេញ លេញនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន ដោយបានអញ្ជើញទៅបោះឆ្នោតយ៉ាងច្រើនកុះករប្រកបដោយភាពថ្លៃថ្នូរ សប្បាយរីករាយ និងតាមឆន្ទៈរបស់ខ្លួន ដើម្បីជ្រើសតាំងតំណាងដែលខ្លួនពេញចិត្តឱ្យបន្តដឹកនាំឃុំ សង្កាត់ ពី ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៧ បន្តទៀត។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានឆ្លុះបញ្ចាំងអំពីភាពចាស់ទុំ នៃដំណើរការប្រជាធិបតេយ្យជាទៀងទាត់នៅកម្ពុជា ជាពិសេសនៅថ្នាក់មូលដ្ឋានក្រោមពន្លឺនៃសន្តិភាព។ ជោគជ័យ នេះក៏ទទួលបាន ក្នុងខណៈដែលព្រះរាជាណាចក្រកម្ពុជា កំពុងងើបឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ និងសម្រេចបាន សមិទ្ធផលថ្មីៗបន្តទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមជាមួយនេះ កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាក៏ កាន់តែត្រូវបានលើកកម្ពស់ ឡើងនៅលើឆាកអន្តរជាតិ ស្របពេលដែលកម្ពុជាកំពុងទទួលតួនាទីជាប្រធានអាស៊ាន និងការត្រៀមធ្វើ ជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ នៅឆ្នាំ២០២៣ខាងមុខ។

សេចក្តីថ្លែងការណ៍បានបញ្ជាក់ដូច្នេះថា៖ «គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឧឡារិកទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាស នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២នេះ។ លទ្ធផលនៃការបោះឆ្នោតនេះ បានកើតចេញពីទឹកចិត្ត ឆន្ទៈ និងវិចារណញ្ញាណរបស់ ប្រជាពលរដ្ឋជាម្ចាស់ឆ្នោតពិតប្រាកដ ដែលមានសេចក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំចំពោះការរីកចម្រើនរបស់ភូមិ ឃុំ សង្កាត់ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួនបន្តទៀត ហើយបានបដិសេធនូវការកុហកបោកប្រាសញុះញង់ មួលបង្កាច់ការពិតរបស់ពួកប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិមួយចំនួនដែលតែងតែរារាំងដំណើរអភិវឌ្ឍន៍កម្ពុជា»។

ការសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតនេះ បានឆ្លុះបញ្ចាំងនូវការផ្តល់យុត្តិធម៌ចំពោះកិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តកម្មវិធីនយោ បាយរបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការគាំទ្រយ៉ាងទូលំទូលាយ

ចំពោះគោលនយោបាយ អភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ របស់គណបក្សប្រជាជនកម្ពុជា។ នេះបើតាមការបញ្ជាក់បន្ថែមរបស់សេចក្តីថ្លែងការណ៍។

គណបក្សប្រជាជនកម្ពុជា ក៏បានសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះជនរួមជាតិ នៅគ្រប់ឃុំ សង្កាត់ ទូទាំងប្រទេស ដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជន កម្ពុជាយ៉ាងច្រើនលើសលប់ ធ្វើឱ្យគណបក្សទទួលបានជោគជ័យដ៏ត្រចះត្រចង់។ តាមរយៈជ័យជម្នះនេះ បានបង្ហាញថា ប្រជាជនបានបោះឆ្នោតជ្រើសរើសយកសន្តិភាព និងការអភិវឌ្ឍដែលមានតម្លៃ លើសអ្វីៗទាំងអស់ ព្រមជាមួយនោះបានពង្រឹងមូលដ្ឋាន សម្រាប់គណបក្សប្រជាជនកម្ពុជា ឈានទៅទទួលបានជ័យជម្នះដ៏ត្រចះត្រចង់ជាថ្មីទៀត ក្នុងការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាឆ្នាំ២០២៣ ខាងមុខ។

គណបក្សប្រជាជនកម្ពុជា ក៏បានសម្តែងនូវការគោរព និងកោតសរសើរ ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ដែលបានបំពេញតួនាទី និងភារ កិច្ចរបស់ខ្លួន ប្រកបដោយភាពឯករាជ្យ អព្យាក្រឹត ឥតលម្អៀង តម្លាភាព និងយុត្តិធម៌ ក្នុងជំហរទទួលខុសត្រូវ ខ្ពស់ចំពោះឧត្តមប្រយោជន៍ជាតិ និងប្រជាជន ធ្វើឱ្យដំណើរការរៀបចំការបោះឆ្នោតនៅគ្រប់ដំណាក់កាលបាន ប្រព្រឹត្តទៅយ៉ាងល្អប្រសើរស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។

គណបក្សប្រជាជនកម្ពុជា ថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាល អាជ្ញាធរដែនដី និងកងកម្លាំងមានសមត្ថកិច្ចនៅគ្រប់លំដាប់ថ្នាក់ ដែលបានយកអស់លទ្ធភាពជួយគាំទ្រ យ៉ាងសកម្មដល់ដំណើរការ រៀបចំការបោះឆ្នោត ជាពិសេស ការការពារសន្តិសុខ សណ្តាប់ធ្នាប់ទូទៅ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត និង ថ្ងៃបោះឆ្នោត ធ្វើឱ្យដំណើរការបោះឆ្នោតបានប្រព្រឹត្ត ទៅយ៉ាងរលូនតាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់។[៥៣]

## គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ បានប្រកាសទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាស កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២២។ លោក ម៉ម សូណង់ដូ បានបញ្ជាក់យ៉ាងដូច្នេះថា "ខ្ញុំអត់មានជម្រើសទេ ត្រូវតែទទួលយក ហើយ១អាសនៈក៏១ដែរ វាគ្រាន់ជាងអត់ សំខាន់សម្រាប់គណបក្សរបស់ខ្ញុំ គឺមិនមែនរឿងជ័យជំនះ សំខាន់គឺការចូលរួមបោះឆ្នោត។ ដូច្នេះខ្ញុំ

---

[៥៣] Fresh News, "គណបក្សប្រជាជនកម្ពុជា ចេញសេចក្តីថ្លែងការណ៍ទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី", "2022-06-26", "http://freshnewsasia.com/index.php/en/localnews/247111-2022-06-26-11-49-38.html" ( accessed date 28-June-2022 at 12 AM)

អបអរសាទរដែលគ.ជ.ប បានរៀបចំការបោះឆ្នោតនេះបានត្រឹមត្រូវ ហើយនៅក្នុងស្ថាប័នជាតិ និងអន្តរជាតិ ក៏គេគាំទ្រ គេសន្និដ្ឋានថា ការបោះឆ្នោតមានតម្លាភាព និងយុត្តិធម៌ ដូច្នេះខ្ញុំអត់មានអីតវ៉ាទេ"។ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ សូមអបអរសាទរចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ បានត្រឹមត្រូវ។[៥៤]

**គណបក្សខ្មែររួបរួមជាតិប្រកាស ទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥**

គណបក្សខ្មែររួបរួមជាតិ របស់លោកញឹក ប៊ុនឆៃ បានប្រកាសទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាស កាលពីថ្ងៃទី២៦ ខែមិថុនា។ នេះបើយោងតាមសេចក្តីថ្លែងការណ៍របស់គណបក្សខ្មែររួបរួមជាតិ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២។ គណបក្សខ្មែររួបរួមជាតិ បានសង្កេតឃើញថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ ទី៥ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ បានប្រព្រឹត្តទៅស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រ កម្ពុជា និងដំណើរការប្រកបដោយលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស គ្មានការបង្ខិតបង្ខំ ក្នុងពេលបោះឆ្នោត មានបរិយាកាសស្ងប់ស្ងាត់ល្អ និងដំណើរការទៅដោយរលូន គ្មានឧបសគ្គ និងគ្មានអំពើហិង្សា ព្រមទាំងការរាប់ សន្លឹកឆ្នោត និងលទ្ធផលបោះឆ្នោតអាចទទួលយកបាន។[៥៥]

**អង្គការ សមាគមក្រៅរដ្ឋាភិបាល ចំនួន១០ ប្រកាសគាំទ្រលទ្ធផល បោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥**

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ នេះ អង្គការ សមាគមក្រៅរដ្ឋាភិបាល ចំនួន១០ បានចេញសេចក្តីថ្លែងការណ៍រួមគ្នា គាំទ្រលទ្ធផលការបោះឆ្នោតនេះទាំងស្រុង ។

សេចក្តីថ្លែងការណ៍របស់អង្គការ សមាគមទាំង១០ មានខ្លឹមសារយ៉ាងដូច្នេះថា ៖ "យើងខ្ញុំទាំងអស់គ្នាតំណាងឱ្យអង្គការ សមាគមក្រៅរដ្ឋាភិបាល ចំនួន ១០ បានតាមដាន និងអង្កេត យ៉ាងយកចិត្ត

[៥៤] រស្មីកម្ពុជា, "លោក ម៉ម សូណង់ដូ : គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥", "JUN 27, 2022", "https://www.rasmeinews.com/archives/661684" ( accessed date 28-June-2022 at 12 AM)

[៥៥] រស្មីកម្ពុជា, "គណបក្សខ្មែររួបរួមជាតិប្រកាសទទួលយកលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥", "JUN 27, 2022", "https://www.rasmeinews.com/archives/661679" ( accessed date 28-June-2022 at 12 AM)

ទុកដាក់បំផុត តាំងពីដំណើរការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល នៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលបានប្រព្រឹត្តទៅ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះ»។ តាមរយៈសេចក្តីថ្លែងការណ៍បានបន្តទៀតថា ទាំងដំណើរការឃោសនាបោះឆ្នោត ដំណើការ បោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល នៃការបោះឆ្នោត គឺបានប្រព្រឹត្តទៅ ប្រកបដោយលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស យុត្តិធម៌ តម្លាភាព គ្មានអំពើហិង្សា និងគ្មានការ គំរាមកំហែង។ «យោងតាមបរិយាកាសដ៏ល្អបំផុត នៃដំណើការបោះឆ្នោតនេះ យើងខ្ញុំតំណាងអង្គការ សមាគម ទាំង១០ សូមប្រកាសគាំទ្រលទ្ធផលជាផ្លូវការ នៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលបានប្រកាសដោយគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ នេះ ទាំងស្រុង»។

សូមបញ្ជាក់ថា អង្គការ សមាគមទាំង១០ ដែលបានចេញសេចក្តីការណ៍គាំទ្រលទ្ធផល នៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ខាងលើ រួមមាន ៖ ទី១. សមាគមសម្ព័ន្ធសារព័ត៌មានឯករាជ្យ (IPA) ដែលមានឯកឧត្តម ទូច វណ្ណៈ ជាប្រធាន។ ទី២. អង្គការលើកកំពស់ជីវភាពកសិករ ដែលមានលោក សក ឡី ជាប្រធាន។ ទី៣. សមាគមពិធីករ ពិធីការិនីកម្ពុជា ដែលមានលោក ទូច សុឃៈ ជាប្រធាន។ ទី៤. អង្គការអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា ដែលលោក ចាវ ប៉េងណាំ ជាប្រធាន។ ទី៥. សមាគមនិស្សិត សិស្សខេត្តព្រៃវែង ដែលមានលោក នីន តារារតន៍ ជាប្រធាន។ ទី៦. អង្គការវិទ្យាស្ថានសបីអភិវឌ្ឍន៍យុវជន ដែលមានលោកជំទាវ ហោ វ៉ាន់នី ជាប្រធាន។ ទី៧. អង្គការសង្គ្រោះបម្រើក្តីសង្ឃឹមពិភពលោក ដែលមានលោក ព្រាប នូរ៉ា ជាប្រធាន។ ទី៨. សមាគមទ្រទ្រង់កសិកម្មធម្មជាតិកម្ពុជា ដែលមានលោកស្រី ព្រីង សុខលាង ជាប្រធាន។ ទី៩. អង្គការអភិវឌ្ឍសមត្ថភាពយុវជនកម្ពុជា ដែលមានលោក សុង ប៊ុនទិត ជាប្រធាន។ និងទី១០. អង្គការត្បូងទទឹមកម្ពុជា ដែលមានលោក ប៊ុន រ៉ូប៊ី ជាប្រធាន ។[៥៦]

## សេចក្តីថ្លែងការណ៍របស់សហភាពសហព័ន្ធយុវជនកម្ពុជា ចំពោះលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥

សហភាពសហព័ន្ធយុវជនកម្ពុជា សូមរក្សាការសោទរចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ឆ្លុះបញ្ចាំងអំពីកិច្ច ដំណើរការល្អនៃប្រជាធិបតេយ្យ នៅកម្ពុជា និងសូមវាយតម្លៃខ្ពស់ចំពោះការបំពេញតួនាទី និងភារកិច្ចប្រកបដោយភាពហ្មត់ចត់ និងទទួលខុសត្រូវ ខ្ពស់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅ គ្រប់កម្រិត ព្រមទាំងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដែលបានធានាឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ ប្រព្រឹត្តទៅ

[៥៦] Trorong, "អង្គការ សមាគមក្រៅរដ្ឋាភិបាល ចំនួន ១០ ប្រកាសគាំទ្រលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥", "BIN BUNNA", "June 27, 2022", "https://troryorng.com/73816/" ( accessed date 28-June-2022 at 12 AM)

ក្នុងបរិយាកាសល្អប្រសើរ គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ ត្រឹមត្រូវ យុត្តិធម៌ ឯករាជ្យភាព និងតម្លាភាព ស្របតាមច្បាប់កំណត់នៃការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា។ ផ្អែកលើមូលដ្ឋាន នៃការវាយតម្លៃនេះ សហភាពសហព័ន្ធយុវជនកម្ពុជា សូមប្រកាសគាំទ្រនូវលទ្ធផលផ្លូវការនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ នេះ គឺពិតជាបានកើតចេញពីការបោះឆ្នោតមួយ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

## សហព័ន្ធនិស្សិតបញ្ញាវ័ន្តប្រជាធិបតេយ្យកម្ពុជា គាំទ្រលទ្ធផលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

សហព័ន្ធនិស្សិតបញ្ញាវ័ន្តប្រជាធិបតេយ្យកម្ពុជា «កែវភ្នែកយុត្តិធម៌» ដែលបានដាក់ភ្នាក់ងារជាង១៣ន់នាក់ សង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២នោះ បានប្រកាសគាំទ្រចំពោះការបោះឆ្នោត ដោយអះអាងថាបានប្រព្រឹត្តទៅដោយរលូន តាមបែបលទ្ធិប្រជាធិបតេយ្យ សេរី និងពហុបក្ស។ តាមរយៈសន្និសីទសារព័ត៌មាន នៅរសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២នេះ នៅវិទ្យាស្ថាន ជាតិអប់រំ, លោក សាខុន ប៉ូរិន អនុប្រធានសហព័ន្ធនិស្សិតបញ្ញាវ័ន្តប្រជាធិបតេយ្យកម្ពុជា បានបញ្ជាក់ថា «ទាក់ទងនឹងដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះ ក្នុងនាមជាក្រុមអ្នកអង្កេត ការណ៍ជាតិ សហព័ន្ធនិស្សិតបញ្ញាវ័នប្រជាធិបតេយ្យកម្ពុជា «កែវភ្នែកយុត្តិធម៌» បានយកចិត្តទុក ដាក់ខ្ពស់ចូលរួមពិនិត្យ តាមដានចាប់ពីថ្ងៃឃោសនារកសម្លេងឆ្នោត ថ្ងៃបោះឆ្នោត និងការត្រួតពិនិត្យ សន្លឹកឆ្នោតឃើញថា នៅគ្រប់នីតិវិធីនីមួយៗសម្រាប់ដំណើរការនៃការបោះឆ្នោតបានប្រព្រឹត្តទៅ យ៉ាង ត្រឹមត្រូវ តម្លាភាព យុត្តិធម៌ និងស្របតាមច្បាប់ ជាពិសេសគឺការប្រកាន់ខ្ជាប់នូវគោលការណ៍ ប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា»។ លោកសង្កត់បន្ថែមថា «សហព័ន្ធនិស្សិតបញ្ញាវ័ន្តប្រជាធិបតេយ្យកម្ពុជា (កែវភ្នែកយុត្តិធម៌) សូមប្រកាសគាំទ្រលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលបានប្រកាសលទ្ធលទ្ធផលផ្លូវការ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២»។[៩៧]

## អ្នកនយោបាយប្រឆាំងថាមិនអាចយកជាការបាន

លោក សម រង្ស៊ី ដែលតែងតែជួយឃោសនាឱ្យគណបក្សភ្លើងទៀន ជាបក្ស ប្រឆាំងដ៏សំខាន់មួយចូលរួមការបោះឆ្នោតនេះ បានចាត់ទុកលទ្ធផលបោះឆ្នោតដែលប្រកាសដោយ គ.ជ.ប. និងគណបក្សប្រជាជនកម្ពុជា ថាមិនអាចយកជាការបានឡើយ។ មិនអាចយកជាការបាន ដែល

---

[៩៧]Fresh News, "សហព័ន្ធនិស្សិតបញ្ញាវ័ន្តប្រជាធិបតេយ្យកម្ពុជា គាំទ្រលទ្ធផលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥", "2022-06-27",
"http://www.freshnewsasia.com/index.php/en/localnews/247204-2022-06-27-10-02-24.html"
( accessed date 28-June-2022 at 12 AM)

បប្រមុខអតីតបក្សប្រឆាំងរូបនេះ អះអាងតាមរបាយការណ៍របស់អង្គការអាមេរិកាំង NDI ថា ជិត ២០% នៃចំនួនឈ្មោះលើបញ្ជីបោះឆ្នោត គឺជាឈ្មោះក្លែងក្លាយ ឬឈ្មោះខ្មោច ហើយថាពលរដ្ឋតែ៦០%ប៉ុណ្ណោះ បានទៅបោះឆ្នោត។ ចំណែកពលរដ្ឋ ៩,៤% ក្នុងចំណោមពលរដ្ឋដែលមានឈ្មោះលើបញ្ជីបោះឆ្នោត តែត្រូវបានគេលុប ឈ្មោះ ចេញពីបញ្ជីនោះទៅវិញ ដែលលោក សម រង្ស៊ី ចោទថា មកពីគណបក្ស ប្រជាជនកម្ពុជា ដឹងថាអ្នកនោះមិនមែនជាអ្នកគាំទ្រខ្លួន។[៥៨]

## គណបក្សនយោបាយ បន្តទាមទារកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត

ស្របពេលលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ បានចេញជាផ្លូវការ កាលពីថ្ងៃអាទិត្យ យើងសង្កេតឃើញថា គណបក្សកាន់ប្រជាជនកម្ពុជា ទទួលបានជ័យជម្នះភ្លូកទឹកភ្លូកដី ហើយគណបក្សនយោបាយ មួយចំនួននៅបន្តជំរុញឱ្យមានការកែទម្រង់ផ្សេងៗជុំវិញការបោះឆ្នោត និងស្ថាប័នរៀបចំការបោះឆ្នោត។

នៅក្នុងសេចក្តីថ្លែងការណ៍មួយ ចេញកាលពីថ្ងៃទី២៦ ខែមិថុនា គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច និងទទួលបានអាសនៈស្ទើរតែទាំងស្រុង បានប្រកាសទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នេះ។

ប៉ុន្តែគណបក្សប្រឆាំងមួយចំនួនបានអះអាងអំពីភាពមិនប្រក្រតីនៃការបោះឆ្នោត ហើយបានលើកឡើងពីភាពមិនទុកចិត្តលើស្ថាប័នរៀបចំការបោះឆ្នោត។

អនុប្រធានគណបក្សភ្លើងទៀន លោក ថាច់ សេដ្ឋា ស្នើសុំឱ្យមានការកែទម្រង់ផ្សេងៗលើស្ថាប័នរៀបចំការបោះឆ្នោត និងការគោរពតាមនីតិវិធីឱ្យត្រឹមត្រូវ ក្រោយពីគណបក្សរបស់លោកសង្កេតឃើញមានភាពមិនប្រក្រតីផ្សេងៗឆ្ពោះទៅកាន់ការបោះឆ្នោត និងអំឡុងពេលបោះ និងរាប់សន្លឹកឆ្នោត។ លោកថ្លែងថា៖ «ដូច្នេះ យើងខ្ញុំគ្រាន់តែទទួលយកបានត្រឹមតែលទ្ធផល ដែលប្រជាពលរដ្ឋលោកបោះឆ្នោតគាំទ្រឱ្យគណបក្សភ្លើងទៀន។ ក៏ប៉ុន្តែភាពមិនប្រក្រតីមួយចំនួននោះគឺយើងមិនទាន់អាចទទួលយកបាននោះទេ ទាល់តែមានការជជែកគ្នាដើម្បីកែលម្អ កែសម្រួលគ.ជ.បមួយចំនួន ដើម្បីអាចធានាដល់ការបោះឆ្នោតនាពេលខាងមុខនេះ ដែលយើងអាចទទួលយកបាន»។ គណបក្សភ្លើងទៀនដែលទើបនឹងដំណើរការសាជាថ្មី ជាគណបក្សទទួលបានសម្លេងគាំទ្រច្រើនជាងគេទីពីរ បន្ទាប់ពីគណបក្សប្រជាជនកម្ពុជា។ បើតាមតួលេខផ្លូវការពីគ.ជ.ប គណបក្សភ្លើងទៀនទទួលបានសម្លេងគាំទ្រជាង១លាន៦សែនសម្លេង ឬ២២,២៥ភាគរយនៃចំនួនសម្លេងឆ្នោតសរុប ហើយទទួលបានអាសនៈសរុប ២.១៩៨ ក្នុងនោះមានមេឃុំចំនួន ៤នាក់ ជំទប់ទីមួយចំនួន ២៥នាក់ និងជំទប់ទីពីរចំនួន ១.៣៦០នាក់។

ស្ថាបនិកគណបក្សកែទម្រង់កម្ពុជា លោក អ៊ូ ច័ន្ទរ័ត្ន សុំមិនធ្វើការអធិប្បាយថា គណបក្សលោកទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឬទេ។ លោកបញ្ជាក់ថានាពេលបច្ចុប្បន្ន គណបក្សកែទម្រង់កម្ពុជា រួមជាមួយគណបក្សមួយចំនួនទៀតកំពុងរៀបចំពាក្យស្នើទៅកាន់គ.ជ.ប ដើម្បី

---

[៥៨] RFI, "បក្សកាន់អំណាចទទួលស្គាល់លទ្ធផលបោះឆ្នោត ខណៈអ្នកនយោបាយប្រឆាំងថាមិនអាចយកជាការបាន", "27/06/2022", "https://rfi.my/8XCv" ( accessed date 28-June-2022 at 12 AM)

សុំឱ្យមានកំណែទម្រង់មួយចំនួន និងចង់ឃើញការផ្លាស់ប្តូរសមាសភាពដឹកនាំរបស់គ.ជ.ប ដែលផ្តើមចេញពីគណបក្សនយោបាយ ដែលលោកថា អាចនាំឱ្យមានការលម្អៀងផ្នែកនយោបាយ។ អតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិរូបនេះក៏បានជំរុញការអនុវត្តឱ្យបានសមស្រប តាមច្បាប់ស្តីពីគណបក្សនយោបាយផងដែរ។ លោកថ្លែងថា៖ «លោកនៅតែយល់ថា បើចូលរួមបោះឆ្នោត ហើយគណបក្សនៅក្រៅរដ្ឋាភិបាលហ្នឹងអាចមានលទ្ធភាពនឹងឈ្នះបាន គង់តែគេរំលាយដដែរ ដូច្នេះធ្វើឱ្យមានការស្ទាក់ស្ទើរពីប្រជាពលរដ្ឋមួយចំនួននោះ»។

ចំណែកប្រធានគណបក្សយុវជនកម្ពុជា លោក ពេជ្រ ស្រស់ បញ្ជាក់ថា លោកយល់ព្រមទទួលលទ្ធផលផ្លូវការនៃការបោះឆ្នោតឃុំសង្កាត់ ក្រោយពីផ្ទៀងផ្ទាត់ឃើញថា ត្រឹមត្រូវស្របតាមលទ្ធផលបោះឆ្នោតបឋម។ ប៉ុន្តែលោកអំពាវនាវឱ្យមានការពង្រឹងលើការយល់ដឹងនិងប្រកាន់ខ្ជាប់កាតព្វកិច្ចរបស់ខ្លួនចំពោះមន្ត្រីអាជ្ញាធរតាមមូលដ្ឋាន ក្រោយពីមានករណីអាជ្ញាធរហៅសកម្មជនគណបក្សនយោបាយទៅសួរនាំ។ លោកថ្លែងថា៖ «ខ្ញុំគ្រាន់តែចង់ឱ្យរដ្ឋាភិបាលធ្វើការពង្រឹងដល់អាជ្ញាធរមូលដ្ឋាន ជាពិសេសឱ្យអាជ្ញាធរមូលដ្ឋានយល់ដឹងពីតួនាទីរបស់ខ្លួនឱ្យបានច្បាស់ មុននឹងធ្វើសកម្មភាពអ្វីមួយពាក់ព័ន្ធនឹងសកម្មជននយោបាយ និងបេក្ខជនគណបក្សនយោបាយ ព្រោះកន្លងមកអាជ្ញាធរហាក់ដូចជា ប្រើតួនាទីប្រឫកប្របល់។ ខ្លួនជាអាជ្ញាធរហៅបេក្ខជនគណបក្សនយោបាយមកសួរនាំ អាហ្នឹងវាអាចធ្វើឱ្យបេក្ខជនគណបក្សនយោបាយតែងតែគិតថា ជាការគំរាមកំហែង។ ហើយមួយទៀតជា សារមួយធ្វើឱ្យបេក្ខជនគណបក្សនយោបាយមានការខ្លាចរអា»។

កាលពីពេលកន្លងទៅ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោក សោម សូរីដា បានច្រានចោលការចោទប្រកាន់នានា ដែលថា គ.ជ.ប មានភាពលម្អៀងទៅរកគណបក្សកាន់អំណាច។ មន្ត្រីជាន់ខ្ពស់របស់គ.ជ.ប រូបនេះបន្តថា គ.ជ.បគ្មានសិទ្ធិអំណាចស្នើឱ្យមានការកែសម្រួលរចនាសម្ព័ន្ធដឹកនាំខ្លួននោះទេ ព្រោះស្ថាប័ននេះអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ និងប្បញ្ញត្តិច្បាប់ផ្សេងទៀតពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោត ហើយក៏បានបំពេញការងាររៀបចំការបោះឆ្នោត ដោយមិនលម្អៀងទៅគណបក្សនយោបាយណាមួយ ឬរំលោភលើក្របខណ្ឌច្បាប់នោះដែរ។[៥៩]

លោកយ៉ង សាំងកុមារ សហស្ថាបនិក គណបក្សប្រជាធិបតេយ្យមូលដ្ឋាន លើកឡើងថា បើទោះជាទទួលយកលទ្ធផលឆ្នោតផ្លូវការបែបណាក្តី ក៏ជំហររបស់គណបក្សប្រជាធិតេយ្យមូលដ្ឋាននៅដដែល ពោលគឺការបោះឆ្នោតលើកនេះ មានស្ថានភាពអាក្រក់ជាងពេលកន្លងមក។ ប៉ុន្តែយ៉ាងមិញលោកគូសបញ្ជាក់ថា គេឈប់គិតលើបញ្ហានេះហើយ គេផ្តើមគិតពីអនាគតទៅមុខទៀតគឺធ្វើការដោយជជែកគ្នារវាងគណបក្សនយោបាយជាមួយគ.ជ.ប និងបណ្តាគណបក្សនយោបាយជាមួយគណបក្សដឹកនាំរដ្ឋាភិបាល ដើម្បីឱ្យការបោះឆ្នោតឆ្នាំ២០២៣ មានលក្ខណៈល្អប្រសើរ។

---

[៥៩] VOA, "គណបក្សនយោបាយខ្លះ បន្តទាមទារកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត", "ណឹម សុភ័ក្រ្តបញ្ញា", "27 មិថុនា 2022", "https://khmer.voanews.com/a/some-political-parties-call-for-election-body-reforms/6634742.html" ( accessed date 28-June-2022 at 12 AM)

លោក សម គន្ធាមី ប្រធានអង្គការនិចហ្វិកដែលធ្វើការងារទាក់ទងដំណើរការបោះឆ្នោត លើកឡើងថា បន្ទាប់ពីលទ្ធផលផ្លូវការបង្ហាញមកបណ្ដាគណបក្សដែលទទួលបានអាសនៈ គួរតែអង្គុយធ្វើការជាមួយគ្នាដោយសន្តិវិធីដើម្បីប្រយោជន៍នៅមូលដ្ឋាន។ ចំពោះករណីដោយឡែកគេចង់ឃើញមេឃុំចៅសង្កាត់- មកពីគណបក្សកាន់អំណាចដែលទទួលបានអាសនៈនាំមុខ ពង្រឹងគុណភាពការងារនៅថ្នាក់មូលដ្ឋានឱ្យកាន់តែប្រសើរឡើង ហើយផ្ដល់សេវាសាធារៈជូនប្រជាជនដោយស្មើភាព និងគ្មានការរើសអើងនិន្នាការនយោបាយ។ បើពុំដូច្នោះទេប្រជាប្រិយភាពរបស់គណបក្សរយៈចំណាស់មួយនេះ នឹងថមថយប្រជាប្រិយភាពដែលស្ដែងឡើងតាមរយៈការបោះឆ្នោត ថ្នាក់ជាតិជ្រើសតាំងតំណាងរាស្ដ្រឆ្នាំ ២០២៣។[៦០]

## ៦.៣. ស្ថានភាពគណបក្សប្រឆាំង ក្រោយការរំលាយ គណបក្សសង្គ្រោះជាតិ ដោយអំណាចតុលាការកំពូល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

យោងតាលទ្ធផលផ្លូវការនៃការបោះឆ្នោត បង្ហាញថាគណបក្សចំនួន៤ ក្នុងចំណោម៦ ដែលបែកចេញពីអតីតគណបក្សសង្គ្រោះជាតិ ហើយដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ បានទទួលសម្លេងគាំទ្រសរុបតែ៥ម៉ឺនសម្លេងប៉ុណ្ណោះ។ សម្លេងឆ្នោតសរុបនេះ មិនបានរាប់បញ្ចូលទាំងគណបក្សភ្លើងទៀន ដែលអ្នកគាំទ្រទាំងអស់ក៏សុទ្ធតែមកពីអតីត គណបក្សសង្គ្រោះជាតិផងដែរ។

ដោយមិនរាប់បញ្ចូលគណបក្សភ្លើងទៀន ក្នុងចំណោមគណបក្សចំនួន៦ ដែលបានបង្កើតបក្សថ្មីក្រោយគណបក្សសង្គ្រោះជាតិត្រូវបានរំលាយ គឺមានគណបក្ស៤ បានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ខណៈគណបក្ស២ផ្សេងទៀតមិនបានចូលរួម។

ក្នុងចំណោមគណបក្សទាំង៤ ដែលមានឈាមជ័រពីអតីតគណបក្សសង្គ្រោះជាតិ រួមមានៈ

ទី១. គណបក្សខ្មែរ ស្រលាញ់ជាតិ របស់លោក ជីវ កត្តា បានទទួលសម្លេងគាំទ្រច្រើនជាងគេ គឺសរុបចំនួន ៣៣,២៥៩ សម្លេង ស្មើ ០.៤៦ភាគរយ និងទទួលបានអាសនៈចំនួន ៥ អាសនៈ, ជំទប់ទី១ ចំនួន២ និងជំទប់ទី២ ចំនួន២ ឈរលំដាប់លេខ៥ក្នុងចំណោម១៧ គណបក្សដែលបានចូលរួមបោះឆ្នោត។

ទី២. គណបក្សកែទម្រង់កម្ពុជា របស់លោក ប៉ុល ហំម និងលោក អ៊ូ ច័ន្ទរ័ត្ន ទទួលបានសម្លេង ៧,៥៥៦សម្លេង ស្មើនឹង ០.១ភាគរយ ឈរនៅលំដាប់លេខ៨ ក្នុងចំណោម១៧គណបក្ស ទទួលបានអាសនៈចំនួន 0 អាសនៈ។

ទី៣. គណបក្សឆន្ទៈខ្មែរ ដែលដឹកនាំដោយក្រុមលោក គង់ គាំ ទទួលបានការ គាំទ្រជាង ៥,០២៤សម្លេង ស្មើនឹង ០.០៧ភាគរយ ឈរលំដាប់ទី១០ ទទួលបានអាសនៈចំនួន 0 អាសនៈ។

---

[៦០] RFI, "ផ្លូវការៈនាំមុនក្នុងការដឹកនាំមូលដ្ឋានជាមួយនឹងសំណូមពរពង្រឹងគុណភាពការផ្ដល់សេវា", "26/06/2022", "https://rfi.my/8X5l" ( accessed date 28-June-2022 at 12 AM)

ទី៤. គណបក្សកម្ពុជានិយម ដែលដឹកនាំដោយលោក យ៉ែម បុញ្ញឫទ្ធិ ឈរលំដាប់ទី១១ ក្នុងចំណោម ១៧គណបក្ស ដោយមានសម្លេងគាំទ្រជាង ៤,៨៥៦សម្លេង ស្មើនឹង ០.០៧ភាគរយ។ ទទួលបានអាសនៈចំនួន ១ អាសនៈ, ជំទប់ទី២ ចំនួន ១១។[៦១]

រីឯគណបក្ស២ផ្សេងទៀត ដែលមិនបានចូលរួមបោះឆ្នោតនេះ មានគណបក្សខ្មែរអភិរក្សនិយម បង្កើតឡើងដោយ លោក រៀល ខេមរិន្ទ អតីតតំណាងរាស្ត្រអតីតគណបក្សសង្គ្រោះជាតិ និងគណបក្សបេះដូងជាតិ របស់លោក សៀម ភ្លុក ដោយសារក្រសួងមហាផ្ទៃមិនទទួលស្គាល់។

ដោយឡែកគណបក្សភ្លើងទៀន ដែលមានប្រវត្តិបង្កើតឡើងដោយលោក សម រង្ស៊ី ពេលនេះកំពុងស្ថិតនៅក្រៅប្រទេសដោយសារជាប់បណ្តឹង និងការផ្តន្ទាទោសជាច្រើនករណីនោះ ហើយពេលនេះបានប្រកាសថា មិនជាប់ពាក់ព័ន្ធនឹង លោក សម រង្ស៊ី ទៀតនោះ ទទួលបានការគាំទ្រ លំដាប់ទី២ បន្ទាប់ពីគណបក្សប្រជាជនកម្ពុជា។ គណបក្សភ្លើងទៀន ទទួលបានសម្លេងសរុបចំនួន ១,៦១០,៥៥៦ សម្លេង ស្មើនឹង ២២.២៥% និងទទួលបានអាសនៈចំនួន ២,១៩៨ អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន ៤ ឃុំ, ជំទប់ទី១ ចំនួន២៥ និងជំទប់ទី២ ចំនួន ១,៣៦០។

សូមរំលឹកថាក្រោយពីទទួលបានសិទ្ធិធ្វើនយោបាយវិញ មន្ត្រីជាន់ខ្ពស់ជាច្រើនក្រុមរបស់អតីតគណបក្សសង្គ្រោះជាតិ បានចេញមកបើកគណបក្សរៀងៗខ្លួនចំនួន៦ ដែលការបើកគណបក្ស ទាំងនេះបានរងការចោទប្រកាន់ថា ជាចេតនានយោបាយចង់បំបែកសម្លេងអតីតគណបក្សសង្គ្រោះជាតិ។ ក៏ប៉ុន្តែក្រុមមន្ត្រី ដែលបានបង្កើតគណបក្សទាំងនោះបដិសេធ និងគូសបញ្ជាក់ថាការបើកគណបក្ស របស់ពួកគេគឺជាសិទ្ធិធ្វើនយោបាយរបស់ពលរដ្ឋ មិនពាក់ព័ន្ធនឹងការទិញដូរដើម្បីបំបែកសម្លេង បក្សប្រឆាំងឡើយ។[៦២]

ជាសរុបមក យើងសង្កេតឃើញថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ ២០២២ នេះ មានប្រជាពលរដ្ឋចេញទៅបោះឆ្នោត សរុបចំនួន ៧,៣៩៤,៤២៧ នាក់ ស្មើនឹង ៨០,៣២% សន្លឹកឆ្នោតបានការសរុបចំនួន ៧.២៣៧.០៣៧សន្លឹក និងសន្លឹកឆ្នោតមិនបានការ សរុបចំនួន ១៥៧.៣៩០ សន្លឹក[៦៣] ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជា ទទួលបានសម្លេងសរុបចំនួន ៥,៣៧៨,៧៧៣សម្លេង ស្មើនឹង ៧៤.៣២% និងទទួលបានអាសនៈចំនួន ៩,៣៧៦អាសនៈ ដោយ

---

[៦១] RFI, "២ក្នុង៤នៃបក្សដែលចេញពីសង្គ្រោះជាតិ ទទួលបានតែ៦អាសនៈពីការបោះឆ្នោតឃុំ-សង្កាត់អាណត្តិទី៥", "25/06/2022", "https://rfi.my/8WwU" (accessed date 28-June-2022 at 12 AM)

[៦២] RFI, "គណបក្ស៤ របស់មន្ត្រីជាន់ខ្ពស់អតីតគណបក្សសង្គ្រោះជាតិបានសម្លេងឆ្នោតសរុបតែ ៥ម៉ឺនសម្លេងប៉ុណ្ណោះ", "08/06/2022", "https://rfi.my/8U27" (accessed date 28-June-2022 at 12 AM)

[៦៣] The National Election Committee, "លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (តារាងសំឡេងឆ្នោត និងភាគរយតាមគណបក្ស)", "https://www.nec.gov.kh/khmer/content/5872" (accessed date 28-June-2022 at 12 AM)

ក្នុងនោះជាប់ជាមេឃុំចំនួន ១៦៤៨ឃុំ, ជំទប់ទី១ ចំនួន១៦១៨ និងជំទប់ទី២ ចំនួន ២៦១ ។ គណបក្សភ្លើងទៀន ទទួលបានសម្លេងសរុបចំនួន ១,៦១០,៥៥៦សម្លេង ស្មើនឹង ២២.២៥% និងទទួលបានអាសនៈចំនួន ២,១៩៨ អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន ៤ឃុំ, ជំទប់ទី១ ចំនួន២៥ និងជំទប់ទី២ ចំនួន ១៣៦០។

បើធៀបនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧[៦៤] កន្លងទៅមានប្រជាពលរដ្ឋចេញទៅបោះឆ្នោត សរុបចំនួន ៧,១០៧,៣៩៥ នាក់ ស្មើនឹង ៩០,៣៧% សន្លឹកឆ្នោតបានការសរុបចំនួន ៦,៩៧៣,៩១១សន្លឹក និងសន្លឹកឆ្នោតមិនបានការ សរុបចំនួន ១៣៣.៤៨៤ សន្លឹក ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជា ទទួលបានសម្លេងសរុបចំនួន ៣,៥៤០,០៥៦សម្លេង ស្មើនឹង៥០.៧៦% និងទទួលបានអាសនៈចំនួន ៦,៥០៣អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន១,១៥៦ ជំទប់ទី១ ចំនួន១,១៣៩ និងជំទប់ទី២ ចំនួន៥១០។ ខណៈដែលគណបក្សសង្គ្រោះជាតិទទួលបាន ៣,០៥៦,៨៤២សម្លេង ស្មើនឹង ៤៣.៨៣%[៦៥] និងទទួលបានអាសនៈចំនួន ៥,០០៧អាសនៈ ដោយក្នុងនោះជាប់ជាមេឃុំចំនួន៤៨៩ ជំទប់ទី១ ចំនួន៥០៣ និងជំទប់ទី២ចំនួន១,០៨៧។

នេះជាភាពជោគជ័យក៏ធំធេងរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ ក្រោយពេលគណបក្សសង្គ្រោះជាតិ ត្រូវបានរំលាយអំណាចតុលាការកំពូល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅ និងបានទទួលបានសិទ្ធិធ្វើនយោបាយឡើងវិញ ហើយមន្ត្រីជាន់ខ្ពស់ជាច្រើនក្រុមរបស់អតីត គណបក្សសង្គ្រោះជាតិបានចេញមកបើកគណបក្សរៀងៗខ្លួនចំនួន៦។

សូមរំលឹកថា គណបក្សភ្លើងទៀន បានចាប់ផ្តើមដំណើរការឡើងវិញ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីបានផ្អាកដំណើរការជាង៤ឆ្នាំកន្លងមក។ បើគិតពីចិរវេលា ដែលបានចាប់ផ្តើមធ្វើសកម្មភាព មានរយៈពេលតែជាង៣ខែប៉ុណ្ណោះ គណបក្សបានរៀបចំរចនាសម្ព័ន្ធគណបក្សឃុំ-សង្កាត់បានចំនួន១៦៣២ឃុំ-សង្កាត់[៦៦] ក្នុងងចំណោមឃុំ-សង្កាត់សរុបចំនួន១៦៥២ នៅទូទាំងប្រទេស

---

[៦៤] The National Election Committee, "លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (តារាងសំឡេងឆ្នោត និងភាគរយតាមគណបក្ស)",

"https://www.nec.gov.kh/khmer/content/4456" (accessed date 28-June-2022 at 12 AM)

[៦៥] The Natioanl Election Committee(NEC), "តារាងគណបក្សនយោបាយទទួលបានអាសនៈ នៃ លទ្ធផលផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧",

"https://www.nec.gov.kh/khmer/content/4457" (accessed date 28-August-2021 at 10 AM)

[៦៦] ថ្មីៗ, "ប្រើពេលតែជាង៣ខែ បក្សភ្លើងទៀន អាចដាក់បេក្ខជនតាមឃុំ-សង្កាត់បានជិត១០០ភាគរយ", "07, Mar 2022", "https://thmeythmey.com/?page=detail&id=113224", (accessed date 28-August-2021 at 10 AM)

ហើយទទួលបានអាសនៈចំនួន ២,១៩៨អាសនៈ ក្នុងចំណោមអាសនៈសរុបចំនួន ១១៦២២អាសនៈ នៅទទូទាំងប្រទេស។ នៅថ្ងៃអាទិត្យទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដែលជាថ្ងៃបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា នាពេលខាងមុខ តើគណបក្សប្រជាជនកម្ពុជា នៅតែអាចរក្សាបាននូវភាពជោគជ័យនេះ ឬ បន្តជោគជ័យបន្ថែមទៀត ឬ យ៉ាងណា?

## សេចក្តីសន្និដ្ឋាន

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលបានប្រកាសលទ្ធផលជាផ្លូវការ នាថ្ងៃអាទិត្យទី២៦ ខែមិថុនា ឆ្នាំ២០២២ ដោយ គ.ជ.ប និងមានគណបក្សចំនួន៩ ក្នុងចំណោមគណបក្ស១៧ដែលបានដាក់បេក្ខភាព ប្រកួតប្រជែង និងក្នុងចំណោមគណបក្សនយោបាយទាំង៤៥ ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ទទួលបានអាសនៈ។ នេះគឺជាលទ្ធផលបោះឆ្នោតមួយដែលគ្រប់ភាគី គណបក្សសុទ្ធតែព្រមទទួលយក ទាំងលើនីតិវិធីនៃការរៀបចំ និងច្បាស់ ដោយហេតុថា ចាប់តាំងពីតំណាក់កាលឃោសនារកសម្លេងឆ្នោត រហូតដល់បោះឆ្នោត និងប្រកាសលទ្ធផលឆ្នោត គឺសុទ្ធតែប្រកបទៅដោយរលូន តាមកាលកំណត់ និងប្រកបដោយអហឹង្សា រាល់បណ្តឹងតវ៉ាសុទ្ធតែត្រូវបានដោះស្រាយ បើទោះបីជាមាន ក្រុមអ្នកសង្កេត ការណ៍អន្តរជាតិមួយចំនួន ដែលបានដាក់អ្នកសង្កេតការណ៍ នាអំឡុងពេល បោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥ បានវាយតម្លៃ និងចាត់ទុកថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្ងៃទី០៥ ខែមិថុនា បានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងក្រុមអ្នកឃ្លាំមើលអន្តរជាតិខ្លះ បានលើកឡើងថា ការបោះឆ្នោតពេលនេះ មិនមានប្រជាធិបតេយ្យ ដ្បិតមានការគាបសង្កត់លើ សិទ្ធិសេរីភាពពលរដ្ឋ និងសហភាពអឺរ៉ុប មិនបានដាក់អ្នកសង្កេតការណ៍សម្រាប់ការបោះឆ្នោតនេះ ដ្បិតយកលេសថាមិនមានវត្តមាននៃគណបក្សប្រឆាំង។

គណបក្សប្រជាជនដែលជាគណបក្សធំតែមួយគត់ ទទួលបានអាសនៈច្រើនលើសលុប និងកាន់តំណែងជាមេឃុំស្ទើរតែទាំងស្រុង ចំណែកគណបក្សភ្លើងទៀន ដែលជាគណបក្សធំទី២ ទទួលបានអាសនៈចំនួន ២,១៩៨អាសនៈ ក្នុងនេះកាន់តំណែងជាមេឃុំចំនួន៤ សុទ្ធតែដាក់ចេញនូវគោលនយោបាយរបស់ខ្លួនរៀងៗខ្លួន ដើម្បីលើកស្ទួយទាំងជីវភាព និងសាវាសាធារណៈ ក្នុងឃុំសង្កាត់របស់ពួកគេ។ ចំណែកគណបក្សមួយចំនួនទៀតដែលទទួលបានអាសនៈតិចតួច បានព្យាយាមគៀងគរគ្នា ដើម្បីធ្វើការកំណែទម្រង់ គ.ជ.ប បន្ថែមទៀត ដោយពួកគេនៅមិនទាន់ពេញចិត្តទាំងស្រុងនឹងគណកម្មាធិការមួយនេះ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ គឺជាជ្រើសរើសតំណាងរបស់ប្រជាពលរដ្ឋ ក្នុងឃុំ-សង្កាត់របស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់។ ពលរដ្ឋជាម្ចាស់ឆ្នោត ការសម្រេចជ្រើសរើសតំណាងរបស់ខ្លួន គឺជាការកំណត់ជោគវាសនាឱ្យភូមិឃុំរបស់ខ្លួន។ ការអនុវត្តឱ្យបានខ្ជាប់ខ្ជួន តាមគោលនយោបាយដែលបានដាក់ចេញ ឬ តាមអ្វីដែលបានសន្យា និងប្រកបដោយប្រសិទ្ធភាព វាគឺកត្តាជំរុញ ដើម្បីឈានទៅរកភាពជោគជ័យ នៅថ្ងៃអាទិត្យទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដែលជាថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភានាពេលខាងមុខ។

ដូច្នេះ ភាពចាំបាច់បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោត ជ្រើសរើងក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានប្រកាសជាផ្លូវការមក បណ្តាគណបក្សដែលទទួលបានអាសនៈ គួរតែអង្គុយធ្វើការជាមួយគ្នាដោយសន្តិវិធី

ដើម្បីផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោតនៅមូលដ្ឋានរបស់ពួកគាត់។ សម្រាប់មេឃុំ-ចៅសង្កាត់ដែលទើបទទួលបានអាសនៈ ជាពិសេសគណបក្សប្រជាជាន ដែលទទួលបានតំណែងជាមេឃុំ-ចៅសង្កាត់ស្ទើរតែទាំងស្រុង គួរតែព្យាយាម ពង្រឹងគុណភាពការងារនៅថ្នាក់មូលដ្ឋានឱ្យកាន់តែប្រសើរឡើងថែមទៀត និងផ្តល់សេវាសាធារៈ ជូនប្រជាជនឱ្យបានស្មើៗភាព និងគ្មានការរើសអើងនិន្នាការនយោបាយ។

-ចប់-